រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប

ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# គោលគំនិតនៃការអភិវឌ្ឍ

# ឃុំ សង្កាត់

ខែសីហា ឆ្នាំ២០១០

NCDD Library
000466

# មាតិកា

សេចក្តីផ្តើម ........................................................................................ i
១. ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍ ........................................................................ ១
១.១. និយមន័យនៃការអភិវឌ្ឍ ........................................................................ ១
១.២. គោលបំណងនៃការអភិវឌ្ឍ ........................................................................៣
១.៣. ទស្សនៈនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព ..........................................៤
១.៤. គោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព .................................៧
២. សមាសភាគសំខាន់ៗដែលត្រូវអភិវឌ្ឍន៍ ...................................................... ៨
២.១. ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច ........................................................................ ៨
២.២. ការអភិវឌ្ឍផ្នែកសង្គម ........................................................................ ១០
២.៣. ការលើកកម្ពស់សិទ្ធិសេរីភាព ........................................................................១៣
២.៤. ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន ..............................................១៩
២.៥. ការកសាងហេដ្ឋារចនាសម្ព័ន្ធ ........................................................................២៤
២.៦. ការអភិវឌ្ឍស្ថាប័ន ........................................................................២៦
៣. បែបបទនៃការអភិវឌ្ឍ ........................................................................៣២
៣.១. បែបបទអភិវឌ្ឍន៍តាមវិស័យ ........................................................................៣២
៣.២. បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន .............................................. ៣៣
៣.៣. បែបបទអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ ........៤២
៤. ដំណើរការនៃគម្រោងអភិវឌ្ឍន៍ ........................................................................៤៩
៤.១. ការសិក្សាអំពីស្ថានភាព ........................................................................៤៩
៤.២. ការរៀបចំផែនការអភិវឌ្ឍន៍ ........................................................................៥២
៤.៣. ការអនុវត្តគម្រោង ........................................................................៥៧
៤.៤. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ .............................................. ៦១

# សេចក្ដីផ្ដើម

មេរៀន ស្ដីពី គោលគំនិតនៃការអភិវឌ្ឍឃុំ សង្កាត់ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្ដល់ចំណេះដឹងជាមូលដ្ឋាន អំពីគោលគំនិតក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដើម្បីជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។

ខ្លឹមសារនៃមេរៀននេះរៀបចំឡើងតាមលក្ខណៈសាមញ្ញ និងងាយយល់ ផ្អែកតាមតម្រូវការ និងស្ថានភាពជាក់ស្ដែងរបស់ឃុំ សង្កាត់។ មេរៀននេះនឹងផ្ដល់ការយល់ដឹងជាមូលដ្ឋានអំពី :

១. ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍ

២. សមាសភាគសំខាន់ៗដែលត្រូវអភិវឌ្ឍន៍

៣. បែបបទនៃការអភិវឌ្ឍ

៤. ដំណើរការនៃគម្រោងអភិវឌ្ឍន៍

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសង្ឃឹមយ៉ាងមុតមាំថា ខ្លឹមសារសៀវភៅនេះនឹងផ្ដល់សារប្រយោជន៍ដល់ការអនុវត្តរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងអ្នកពាក់ព័ន្ធទាំងអស់។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិស្វាគមន៍ជានិច្ចនូវរាល់មតិទិតៀនស្ថាបនា ដើម្បីកែលម្អសៀវភៅនេះកាន់តែប្រសើរឡើង។

# ១. ទិដ្ឋភាពទូទៅនៃការអភិវឌ្ឍ

## ១.១. និយមន័យនៃការអភិវឌ្ឍ

ការអភិវឌ្ឍ គឺជាការលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានសុវត្ថិភាពស្បៀងអាហារ ប្រាក់ចំណូល ធនធានមនុស្ស សិទ្ធិសេរីភាព ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងនិរន្តរភាពធនធានធម្មជាតិ និងលំនឹងបរិស្ថាន ។ល។

ធនធានសំខាន់ៗដែលបង្ហាញអំពីសក្តានុពលនៃការអភិវឌ្ឍមាន :

- **ធនធានហិរញ្ញវត្ថុ** : ទ្រព្យសម្បត្តិ ប្រាក់ចំណូល មធ្យោបាយផលិតកម្ម
- **ធនធានមនុស្ស** : ការអប់រំ (ចំណេះដឹង ជំនាញបច្ចេកទេស និងឥរិយាបថ) សុខភាព
- **ធនធានសង្គម** : លទ្ធិប្រជាធិបតេយ្យ ការគ្រប់គ្រង សមាគម ទំនាក់ទំនង ច្បាប់ និងគណនេយ្យភាព
- **ធនធានធម្មជាតិ** : ផលដែលបានមកពីធម្មជាតិ និងលំនឹងបរិស្ថាន
- **ហេដ្ឋារចនាសម្ព័ន្ធ** : បណ្តាញប្រព័ន្ធគមនាគមន៍ សំណង់ អគារ ប្រព័ន្ធធារាសាស្ត្រ និងបណ្តាញអគ្គិសនី ។ល។




## ធនធានសំខាន់ៗដែលបង្ហាញអំពីសក្តានុពលនៃការអភិវឌ្ឍ

ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់អាចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនដូចជា :

- ការបង្កើនប្រាក់ចំណូល និងសុវត្ថិភាពស្បៀងរបស់ប្រជាពលរដ្ឋ ដោយសាងសង់ប្រព័ន្ធធារាសាស្ត្រ និងផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ដើម្បីបង្កើនទិន្នផលកសិកម្ម
- កសាងធនធានមនុស្ស ដោយសាងសង់សាលារៀន និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្តល់ការអប់រំ បំណិនជីវិត និងជំនាញបច្ចេកទេសដល់ប្រជាពលរដ្ឋ
- ផ្សព្វផ្សាយអំពីច្បាប់ សិទ្ធិមនុស្ស និងការបញ្ជ្រាបយេនឌ័រ ដើម្បីបង្កើនការយល់ដឹង ការគោរពច្បាប់ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍឃុំ សង្កាត់

- សាងសង់ផ្លូវថ្នល់ ដើម្បីសម្រួលការដឹកជញ្ជូនកសិផលទៅកាន់ទីផ្សារ និងការធ្វើដំណើររបស់ប្រជាពលរដ្ឋទៅកាន់មណ្ឌលសុខភាព ឬ សាលារៀន
- បំផុសប្រជាពលរដ្ឋចូលរួមការពារព្រៃឈើ និងបង្កើតសហគមន៍ព្រៃឈើ ដើម្បីបង្កើនធនធានព្រៃឈើ ការពារការហូរច្រោះដី ការពារប្រភពទឹក និងការថែរក្សាលំនឹងបរិស្ថាន
- . . . ។ល។

## ១.២. គោលបំណងនៃការអភិវឌ្ឍ

ការអភិវឌ្ឍមានគោលបំណង :

- ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច
- លើកកម្ពស់សេវាសង្គម
- លើកកម្ពស់សិទ្ធិសេរីភាព

### ក). ការធ្វើឱ្យមានកំណើនសេដ្ឋកិច្ច

ការធ្វើឱ្យមានកំណើនសេដ្ឋកិច្ច គឺជាការធ្វើឱ្យកម្រិតប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកើនឡើងដូចជា ការអភិវឌ្ឍវិស័យកសិកម្ម ការផ្ដល់ទុនបង្កើតមុខរបរ ការអភិវឌ្ឍវិស័យសិប្បកម្ម និងឧស្សាហកម្មខ្នាតតូច ។ល។

### ខ). ការលើកកម្ពស់សេវាសង្គម

ការលើកកម្ពស់សេវាសង្គម គឺជាការធ្វើឱ្យសេវាសង្គមកាន់តែមានគុណភាព និងប្រសិទ្ធភាព ដូចជា ការអភិវឌ្ឍវិស័យសុខាភិបាល វិស័យអប់រំ កិច្ចការពារស្ត្រី កុមារ និងជនងាយរងគ្រោះ ។ល។

### គ). ការលើកកម្ពស់សិទ្ធិសេរីភាព

ការលើកកម្ពស់សិទ្ធិសេរីភាព គឺជាការធ្វើឱ្យប្រសើរឡើងដល់សិទ្ធិ និងគុណតម្លៃនៃការរស់នៅរបស់ប្រជាពលរដ្ឋ ដូចជា សិទ្ធិសេរីភាពក្នុងការទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយយុត្តិធម៌ សមភាព លទ្ធិប្រជាធិបតេយ្យ សិទ្ធិចូលរួមក្នុងសកម្មភាពនយោបាយ និងសិទ្ធិទទួលបានព័ត៌មាន ។ល ។

## ១.៣. ទស្សនៈនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព

### ក). និយមន័យនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព គឺជាការអភិវឌ្ឍដែលបានឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ន ហើយមិនធ្វើឱ្យបាត់បង់ផលិតភាព ក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅពេលអនាគត ។

សេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ រួមមាន សេចក្តីត្រូវការខាងផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាន ។

ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ជាទស្សនៈអភិវឌ្ឍន៍មួយដែលយកចិត្តទុកដាក់ក្នុងការលើកកម្ពស់តម្លៃប្រជាពលរដ្ឋ ថែរក្សាសត្វ រុក្ខជាតិ ធនធានធម្មជាតិ និងបរិស្ថាន ដើម្បីជួយកាត់បន្ថយភាពក្រីក្រ ធ្វើឱ្យមានសមភាពយេនឌ័រ ការគោរពសិទ្ធិមនុស្ស ប្រជាពលរដ្ឋទទួលបានការអប់រំ សេវាថែទាំសុខភាព និងធានាសុវត្ថិភាពរបស់ប្រជាពលរដ្ឋ ។ល ។




គំនូសបំព្រួញនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព

ខ). **ស្ថិរភាព**

ស្ថិរភាព សំដៅលើការអភិវឌ្ឍដែលបានយកចិត្តទុកដាក់ទាំងផ្នែកសេដ្ឋកិច្ច និងការអភិរក្សបរិស្ថាន ដើម្បីធ្វើឱ្យមានការរីកចម្រើនខាងផ្នែកសេដ្ឋកិច្ច និងរក្សាបាននូវលំនឹងបរិស្ថាន។

**ឧទាហរណ៍**

ឃុំសង់ផ្លូវមួយខ្សែ ហើយផ្លូវនេះត្រូវសង់កាត់មុខទឹកហូរ ឃុំក៏បានសង់ស្ពានមួយ ដើម្បីសម្រួលចរន្តទឹកហូរឱ្យមានលក្ខណៈដូចដើម ដោយសារបរិស្ថានតំបន់នេះមិនមានផលប៉ះពាល់ជាអវិជ្ជមាន ធ្វើឱ្យតំបន់នេះរក្សាបានស្ថានភាពរូបសាស្ត្រ និងជីវសាស្ត្របានជាធម្មតា ហើយផ្លូវដែលសាងសង់រួចអាចស្ថិតក្នុងស្ថានភាពរឹងមាំ និងពុំមានការបំផ្លាញដោយធម្មជាតិ ទាំងនេះធ្វើឱ្យបរិស្ថាន និងសេដ្ឋកិច្ចប្រជាពលរដ្ឋមានស្ថេរភាព។ ផ្ទុយទៅវិញ បើឃុំពុំគិតពីស្ថានភាពបរិស្ថានទីតាំងនេះទេ ពេលមានទឹកជន់ខ្លាំងនឹងធ្វើឱ្យលិចលង់ ហើយ

អាចឈានទៅបំផ្លាញផលដំណាំ ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ឬអាចបំផ្លាញផ្លូវ ដែលបានសាងសង់នេះទៀតផង ។

### គ). សមភាព

សមភាព សំដៅលើការអភិវឌ្ឍដែលបានយកចិត្តទុកដាក់ទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម ដើម្បីធ្វើឱ្យអ្នកពាក់ព័ន្ធទាំងអស់ស្មើភាពគ្នាក្នុងការទទួលបានចំណូល និងផលប្រយោជន៍ពីការអភិវឌ្ឍ ហើយអាចរស់នៅក្នុងសង្គមមួយមានសុខដុមរមនា ។

**ឧទាហរណ៍**

ឃុំ សង្កាត់បានជ្រើសរើសគម្រោងអាទិភាពដែលអាចជួយដល់ស្ត្រី ជនងាយរងគ្រោះ និងប្រជាពលរដ្ឋក្រីក្រ ជួយដល់ពួកគាត់ឱ្យមានលទ្ធភាពទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍ និងជួយសម្រួលដល់ជីវភាពរស់នៅរបស់ពួកគាត់ក្នុងការរស់នៅក្នុងសង្គមមួយសមស្រប និងជាឱកាសមួយ ដើម្បីឱ្យប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះទាំងនេះ ដោះស្រាយការលំបាកបច្ចុប្បន្ន និងបង្កើនឱកាសសម្រាប់ការរីកចម្រើននាពេលអនាគត ដើម្បីកាត់បន្ថយកម្លាតផ្នែកសេដ្ឋកិច្ច ក៏ដូចជា ផ្នែកសង្គមរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ ។

### ឃ). ភាពបន្សាំ

ភាពបន្សាំ សំដៅលើការអភិវឌ្ឍដែលបានយកចិត្តទុកដាក់ទាំងផ្នែកសង្គម និងបរិស្ថាន ដើម្បីធ្វើឱ្យលទ្ធភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋក្នុងល័ក្ខខ័ណ្ឌថ្មីមានភាពប្រក្រតី ។

**ឧទាហរណ៍**

ការផ្លាស់ប្តូរពីទម្លាប់ដាំដុះប្រភេទស្រូវប្រកាន់រដូវ មកប្រភេទស្រូវមិនប្រកាន់រដូវ ឬប្រភេទស្រូវធ្ងន់ មកស្រូវស្រាលនៅពេលដែលអាកាសធាតុមានភាពប្រែប្រួល និងជួបប្រទះភាពរាំងស្ងួតញឹកញាប់ ទន្ទឹមនឹងការផ្លាស់ប្តូរប្រភេទស្រូវដាំដុះ ប្រជាពលរដ្ឋត្រូវផ្លាស់ប្តូរបច្ចេកទេសដាំដុះ របៀបរបបការងារ និងបែបបទរស់នៅផងដែរ ដើម្បីឱ្យស្របតាមល័ក្ខខ័ណ្ឌបរិស្ថានដែលខ្លួនរស់នៅ។

## ១.៤. គោលការណ៍នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព

ការអភិវឌ្ឍប្រកបដោយនិរន្តរភាពត្រូវមានគោលការណ៍មួយចំនួនដូចខាងក្រោម :

- ឆ្លើយតបនឹងសេចក្តីត្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋទូទៅ
- កាត់បន្ថយហានិភ័យដល់ធនធានធម្មជាតិ និងបរិស្ថានជាអតិបរមា
- ធ្វើឱ្យជីវភាពប្រជាពលរដ្ឋមានការផ្លាស់ប្តូរកាន់តែប្រសើរឡើង
- ដំណើរការអនុវត្តប្រកបដោយសមធម៌ យុត្តិធម៌ និងស្ថិរភាព
- ធ្វើឱ្យមានសុខដុមនីយកម្មក្នុងបណ្តាអ្នកពាក់ព័ន្ធទាំងអស់
- បង្កើនការចូលរួមពីអ្នកពាក់ព័ន្ធក្នុងសកម្មភាពអភិវឌ្ឍន៍
- ការអភិវឌ្ឍប្រកបដោយសមភាពយេនឌ័រ
- . . .ល។

# ២. សមាសភាគសំខាន់ៗដែលត្រូវអភិវឌ្ឍន៍

សមាសភាគសំខាន់ៗដែលត្រូវអភិវឌ្ឍន៍មានដូចខាងក្រោម :

- ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច
- ការអភិវឌ្ឍផ្នែកសង្គម
- ការលើកកម្ពស់សិទ្ធិសេរីភាព
- ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន
- ការកសាងហេដ្ឋារចនាសម្ព័ន្ធ និង
- ការអភិវឌ្ឍស្ថាប័ន។

## ២.១. ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច

### ក). វិស័យកសិកម្ម

ការអភិវឌ្ឍផ្នែកសេដ្ឋកិច្ច សំដៅលើសកម្មភាពអភិវឌ្ឍន៍ទាំងឡាយណាដែលជួយដោយផ្ទាល់ដល់ការលើកកម្ពស់ចំណូលរបស់ប្រជាពលរដ្ឋ។ វិស័យកសិកម្មដំណាំស្រូវ ប្រកពចំណូលចម្បងរបស់ប្រជាពលរដ្ឋដែលរស់នៅតាមជនបទ។ វិស័យកសិកម្ម រួមមាន ការដាំដុះដំណាំស្រូវ ការធ្វើដំណាំចំការ ការចិញ្ចឹមសត្វ និងនេសាទ ។ល។

### ក.១). សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពកសិកម្មដំណាំស្រូវ

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពកសិកម្មដំណាំស្រូវដូចជា :

- ទំហំផ្ទៃដីកសិកម្មក្នុងគ្រួសារនីមួយៗ
- ប្រព័ន្ធធារាសាស្ត្រ

- ចំនួនរដូវដាំដុះដំណាំស្រូវក្នុងមួយឆ្នាំ
- ទិន្នផលស្រូវ ( តោន/ហិកតា)
- បរិមាណស្រូវប្រជាពលរដ្ឋម្នាក់ក្នុង១ឆ្នាំ ( គក្រ/ម្នាក់/ឆ្នាំ)
- តម្លៃស្រូវក្នុងមួយគីឡូក្រាម
- មធ្យោបាយផលិតកម្ម និងកម្លាំងអូសទាញ ។

## ក.២).សកម្មភាពឃុំក្នុងការអភិវឌ្ឍវិស័យកសិកម្ម

ក្រុមប្រឹក្សាឃុំ សង្កាត់អភិវឌ្ឍន៍វិស័យកសិកម្មនៅឃុំ សង្កាត់តាមរយៈ :

- ការសាងសង់ប្រព័ន្ធធារាសាស្ត្រ ដូចជា ជីកប្រឡាយ សង់ទំនប់ សង់ស្ថានីយបូមទឹក
- ការផ្សព្វផ្សាយ និងការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម
- ការផ្តល់ពូជស្រូវ ពូជបន្លែ និងពូជសត្វពាហនៈ
- បង្កើនមធ្យោបាយផលិតកម្ម ដូចជា មាស៊ីនបូមទឹក ម៉ាស៊ីនកិនស្រូវ កម្លាំងអូសទាញ និងសម្ភារកសិកម្មនានា
- ការផ្តល់ឥណទានសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម
- ការផ្តល់សេវាការពារ និងការចាក់ថ្នាំបង្ការជំងឺសត្វពាហនៈ ។

## ខ). វិស័យនានាមិនមែនកសិកម្ម

ក្រៅពីវិស័យកសិកម្ម ប្រជាពលរដ្ឋនៅមូលដ្ឋានអាចរកចំណូលពីវិស័យមិនមែនកសិកម្ម ដូចជា ជំនួញខ្នាតតូច សិប្បកម្ម និងឧស្សាហកម្មខ្នាតតូច ។ល។ ដោយឡែក ប្រជាពលរដ្ឋមួយចំនួនក្រៅពីប្រកបការងារកសិកម្ម ក៏បានប្រកបកិច្ចការទាំងនោះផងដែរ ដើម្បីរកចំណូលបន្ថែម ។

## ២.២. ការអភិវឌ្ឍផ្នែកសង្គម

ការអភិវឌ្ឍផ្នែកសង្គម សំដៅលើសកម្មភាពអភិវឌ្ឍន៍ទាំងឡាយណាដែលធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព និងលើកកម្ពស់សមត្ថភាពរបស់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍផ្នែកសង្គមរួមមាន ការលើកកម្ពស់សុខភាព ការអប់រំ និងសមភាពយេនឌ័រ ។ល។

### ក). សុខភាព

### ក.១). សារប្រយោជន៍នៃសុខភាព

សុខភាព និងការអភិវឌ្ឍមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ មានន័យថា ប្រជាពលរដ្ឋមានសុខភាពល្អ នោះនឹងនាំឱ្យប្រជាពលរដ្ឋមានកម្លាំងមាំមួន ប្រាជ្ញាភ្លឺថ្លាក្នុងការប្រកបកិច្ចការផ្សេងៗ ដូចជា ការសិក្សារៀនសូត្រ ការប្រកបការងារកសិកម្ម និងចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍នានា ។ល។

ផ្ទុយទៅវិញ នៅពេលដែលប្រជាពលរដ្ឋមិនមានសុខភាពល្អ ពួកគាត់ត្រូវការចំណាយពេលវេលាក្នុងការសម្រាកព្យាបាលជំងឺ ចំណាយថវិកាសម្រាប់សេវាសុខភាព មិនមានពេលវេលាប្រកបការងារ ឬចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍នានាឡើយ ។ កត្តាទាំងនេះធ្វើឱ្យប្រជាពលរដ្ឋក្រីក្រ ។

### ក.២).សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពសុខភាពប្រជាពលរដ្ឋ

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពសុខភាពប្រជាពលរដ្ឋនៅឃុំ សង្កាត់មានដូចខាងក្រោម :

- អត្រាមរណៈរបស់មាតា និងទារក
- កម្រិតយល់ដឹងអំពីអនាម័យ និងការការពារជំងឺ

- ភាគរយប្រជាពលរដ្ឋបានទទួលសេវាសុខភាព
- ភាគរយគ្រួសារដែលមានបង្គន់អនាម័យប្រើប្រាស់
- ចំនួនគ្រួសារប្រើប្រាស់អណ្តូងមួយ
- ចំនួនប្រជាពលរដ្ឋប្រើប្រាស់ទឹកមានសុវត្ថិភាព

**គ.៣).សកម្មភាពឃុំ សង្កាត់ក្នុងការលើកកម្ពស់សុខភាពប្រជាពលរដ្ឋ**

ក្រុមប្រឹក្សាឃុំ សង្កាត់លើកកម្ពស់សុខភាពប្រជាពលរដ្ឋក្នុងឃុំ សង្កាត់តាមរយៈ :

- សាងសង់អណ្តូងទឹក ស្រះទឹក និងអប់រំប្រជាពលរដ្ឋឱ្យទុកដាក់ និងប្រើប្រាស់ទឹកមានសុវត្ថិភាព
- ចលនាប្រជាពលរដ្ឋសាងសង់បង្គន់អនាម័យ និងបញ្ឈប់ការបន្ទោរបង់ពាសវាលពាសកាល
- សាងសង់មណ្ឌលសុខភាព ដើម្បីបម្រើដល់ការថែទាំសុខភាព និងការព្យាបាលជំងឺនានារបស់ប្រជាពលរដ្ឋ
- អប់រំផ្សព្វផ្សាយប្រជាពលរដ្ឋឱ្យយល់ដឹងពីអនាម័យចាក់ថ្នាំបង្ការ ផ្តល់ជីវជាតិបន្ថែម ការពារមេរោគអេដស៍ និងទទួលសេវាថែទាំសុខភាពនៅមណ្ឌលសុខភាព។

**ខ). ការអប់រំ**

ការអប់រំ សំដៅលើការសិក្សារៀនសូត្ររបស់ប្រជាពលរដ្ឋក្នុងការទទួលបានចំណេះដឹង ជំនាញ សីលធម៌ល្អ និងបំណិនជីវិត។ ការអប់រំត្រូវបាន

ទទួលស្គាល់ និងចាត់ទុកជាគន្លឹះសំខាន់មួយក្នុងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។

**ខ.១). សារប្រយោជន៍នៃការអប់រំ**

ប្រជាពលរដ្ឋដែលបានទទួលការអប់រំអាចជំរុញវិស័យសេដ្ឋកិច្ច សង្គម សិទ្ធិមនុស្ស ការគ្រប់គ្រងធនធានធម្មជាតិ និងការថែរក្សាបរិស្ថានមានប្រសិទ្ធភាព។ សារប្រយោជន៍នៃការអប់រំជួយឱ្យប្រជាពលរដ្ឋ :

- បង្កើនសមត្ថភាពផលិត ក្នុងការងារកសិកម្ម សិប្បកម្ម ជំនួញ
- បង្កើនបំណិនជីវិតរស់នៅប្រចាំថ្ងៃ ដូចជា ការយល់ដឹង ទំនាក់ទំនង
- មានជំនឿទុកចិត្តលើសមត្ថភាពខ្លួន និងបំពេញការងារបានល្អ
- មានលទ្ធភាព និងឱកាសច្រើនក្នុងការស្វែងរកការងារធ្វើ
- រកការងារដែលទទួលបានកម្រៃខ្ពស់ជាងអ្នកមិនចេះអក្សរ
- ធ្វើការសម្រេចចិត្តប្រកបដោយហេតុផល និងមានការថ្លឹងថ្លែង។

**ខ.២). សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពអប់រំ**

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពអប់រំនៅឃុំ សង្កាត់មានដូចខាងក្រោម :

- អត្រាកុមារចុះឈ្មោះចូលរៀន និងចូលរៀនគ្រប់ភូមិសិក្សា
- អត្រាប្រជាពលរដ្ឋចេះអក្សរ
- កម្រិតសិក្សារបស់ប្រជាពលរដ្ឋ
- អត្រាសិស្សបោះបង់ការសិក្សា
- ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារអប់រំ។

### ១.៣). ការសិក្សាអប់រំសម្រាប់ប្រជាពលរដ្ឋ

ប្រជាពលរដ្ឋអាចទទួលបានការអប់រំ តាមរយៈ :

- ការអប់រំក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ
- ការអប់រំនៅសាលារៀនរដ្ឋ និងសាលារៀនឯកជន
- ការសិក្សាចំណេះដឹងទូទៅ និងជំនាញឯកទេស
- ការបណ្តុះបណ្តាលរយៈពេលវែង និងរយៈពេលខ្លី
- ការសិក្សាបច្ចេកទេសកម្រិតបឋម កម្រិតមធ្យម ឬកម្រិតជាន់ខ្ពស់

### ១.៤). សកម្មភាពឃុំ សង្កាត់ក្នុងការលើកកម្ពស់ការអប់រំ

ក្រុមប្រឹក្សាឃុំ សង្កាត់លើកកម្ពស់ការអប់រំប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ តាមរយៈ :

- ការសាងសង់សាលារៀននៅតាមឃុំ សង្កាត់
- ការរៀបចំ និងការបង្កើតមត្តេយ្យសិក្សាសហគមន៍
- ការអប់រំផ្សព្វផ្សាយ និងចលនាប្រជាពលរដ្ឋឱ្យបញ្ជូនកូនទៅរៀន
- សហការជាមួយមន្ទីរជំនាញ និងអ្នកពាក់ព័ន្ធក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរបស់ប្រជាពលរដ្ឋ

## ២.៣. ការលើកកម្ពស់សិទ្ធិសេរីភាព

ការលើកកម្ពស់សិទ្ធិសេរីភាព សំដៅលើសកម្មភាពអភិវឌ្ឍន៍ដែលធ្វើឱ្យប្រជាពលរដ្ឋមានសមភាព យុត្តិធម៌ សិទ្ធិប្រជាធិបតេយ្យ សិទ្ធិទទួលបានសេវានានា ការរស់នៅប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ។

## ក). ប្រភេទនៃសិទ្ធិមនុស្ស

សិទ្ធិមនុស្សមាន៣ប្រភេទសំខាន់ៗគឺ :

- សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- សិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌
- សិទ្ធិទទួលបានសន្តិភាព អភិវឌ្ឍន៍ និងបរិស្ថាន

### ក.១). សិទ្ធិពលរដ្ឋ និងនយោបាយ

- **សិទ្ធិពលរដ្ឋ**
  - សិទ្ធិដើម្បីរស់រានមានជីវិត
  - សិទ្ធិដើម្បីមានសេរីភាព
  - សិទ្ធិរួចផុតពីការធ្វើទារុណកម្ម
  - សិទ្ធិស្មើភាពនៅចំពោះមុខច្បាប់
  - សិទ្ធិរួចផុតពីការរើសអើង
  - សិទ្ធិឱ្យមានច្បាប់ការពារ
  - សិទ្ធិមានសញ្ជាតិ
  - សិទ្ធិមានឈ្មោះ
  - សិទ្ធិប្រព្រឹត្តតាមដំណើរការច្បាប់
  - សិទ្ធិប្រើប្រាស់ប្រព័ន្ធតុលាការ
  - សិទ្ធិទទួលយក ស្វែងរក និងចែកចាយព័ត៌មាន
  - សិទ្ធិមានមនសិការ និងបញ្ចេញមតិដោយសេរី

- សិទ្ធិមានសន្តិសុខក្នុងលំនៅដ្ឋានឯកជនរបស់ខ្លួន
- សិទ្ធិសេរីភាពក្នុងការធ្វើដំណើរ
- សិទ្ធិតាំងលំនៅដ្ឋាន
- សិទ្ធិអាពាហ៍ពិពាហ៍
- ...។ល។

- **សិទ្ធិនយោបាយ**
  - សិទ្ធិបញ្ចេញមតិដោយសេរី
  - សិទ្ធិចូលរួមប្រជុំ
  - សិទ្ធិបង្កើតសមាគម
  - សិទ្ធិបោះឆ្នោតដោយសេរី
  - សិទ្ធិចូលរួមក្នុងឆាកនយោបាយ
  - សិទ្ធិស្មើគ្នាទទួលបានសេវាកម្មសាធារណៈ (រួមទាំងសិទ្ធិទទួលការជ្រើសរើសឱ្យកាន់ដំណែងការងារ)

**ក.២).សិទ្ធិសង្គម សេដ្ឋកិច្ច និងវប្បធម៌**

- សិទ្ធិមានការងារធ្វើ
- សិទ្ធិជ្រើសរើសការងារ
- សិទ្ធិមានទ្រព្យសម្បត្តិជាកម្មសិទ្ធិ
- សិទ្ធិមានកម្រិតជីវភាពសមរម្យ
- សិទ្ធិទទួលបានការអប់រំ

- សិទ្ធិបង្កើតគ្រួសារ
- សិទ្ធិមានសន្តិសុខសង្គម
- សិទ្ធិមានការធានារ៉ាប់រង
- សិទ្ធិទទួលកិច្ចឧបត្ថម្ភខាងសង្គមកិច្ច និងសុខាភិបាល
- សិទ្ធិមានអាហារគ្រប់គ្រាន់
- សិទ្ធិទទួលបានការសម្រាក និងការកំសាន្តកាយ
- សិទ្ធិចូលរួមដោយសេរីក្នុងជីវភាពវប្បធម៌

**ក.៣).សិទ្ធិទទួលបានសន្តិភាព អភិវឌ្ឍន៍ និងបរិស្ថាន**

សិទ្ធិទទួលបានសន្តិភាព អភិវឌ្ឍន៍ និងបរិស្ថាន មានចែងក្នុងកម្រង ច្បាប់អន្តរជាតិជាច្រើន ដូចជា អនុសញ្ញានានាដែលឆ្លើយតបទៅនឹងសេចក្តី ត្រូវការរបស់មនុស្សក្នុងការរក្សាសន្តិភាព ជំរុញការអភិវឌ្ឍ និងការកែលម្អ បរិស្ថាន ។ល ។

**ខ). តម្លៃជាមូលដ្ឋានរបស់សិទ្ធិមនុស្ស**

តម្លៃជាមូលដ្ឋានរបស់សិទ្ធិមនុស្ស គឺ :

- **ជីវិត** : ជីវិតត្រូវទ្រទ្រង់ និងការពារដោយយកចិត្តទុកដាក់
- **សេរីភាព** : ពលរដ្ឋគ្រប់រូបមានសេរីភាពផ្ទាល់ខ្លួន ប៉ុន្តែការប្រើប្រាស់សេរីភាពនោះមិនត្រូវឱ្យប៉ះពាល់ដល់សេរីភាពអ្នកដទៃ
- **សមភាព និងការមិនរើសអើង** : ពលរដ្ឋគ្រប់រូបត្រូវបានទទួលស្គាល់ និងគោរពតម្លៃស្មើៗគ្នា ដោយគ្មានការប្រកាន់ពូជសាសន៍ ពណ៌សម្បុរ បក្សពួក ឬសាសនា

- **យុត្តិធម៌** : ពលរដ្ឋគ្រប់រូបត្រូវបានច្បាប់ការពារប្រកបដោយយុត្តិធម៌
- **សាមគ្គីភាព** : ពលរដ្ឋគ្រប់រូបត្រូវមានភាពស្មោះត្រង់ យោគយល់អធ្យាស្រ័យ ចេះជួយគ្នាទៅវិញទៅមក និងមានតម្លាភាព
- **ការទទួលខុសត្រូវក្នុងសង្គម** : ពលរដ្ឋគ្រប់រូបមានកាតព្វកិច្ចចំពោះខ្លួនឯងផង និងចំពោះសង្គមផង
- **សន្តិភាព និងអហិង្សា** : ពលរដ្ឋគ្រប់រូបត្រូវមានសន្តិភាពក្នុងចិត្ត និងអហិង្សាក្នុងទង្វើគ្រប់យ៉ាង
- **ការគោរពមនុស្ស ថែរក្សាធម្មជាតិ សត្វ និងរុក្ខជាតិ** : មនុស្សជាតិអាចស្ថិតស្ថេរបាន អាស្រ័យដោយការគោរពចំពោះមនុស្ស និងថែរក្សាសត្វ និងធម្មជាតិ ដូចជា ព្រៃឈើ ទន្លេ។ល។ ដែលជាសេចក្តីត្រូវការចាំបាច់របស់មនុស្ស។

**គ). សារប្រយោជន៍នៃការគោរពសិទ្ធិមនុស្សចំពោះការអភិវឌ្ឍ**

សារប្រយោជន៍នៃការគោរពសិទ្ធិមនុស្សជួយដល់ការអភិវឌ្ឍដូចជា :

- លើកកម្ពស់ការចូលរួមក្នុងការអភិវឌ្ឍ
- បង្កើនគណនេយ្យភាពនៅក្នុងកិច្ចការសាធារណៈ
- ជួយពង្រឹងអភិបាលកិច្ចល្អក្នុងការអភិវឌ្ឍ
- ធ្វើឱ្យមានសមភាព និងយុត្តិធម៌ក្នុងការទទួលផលប្រយោជន៍។

### ឃ). សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពសិទ្ធិសេរីភាព

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋនៅឃុំ សង្កាត់មានដូចខាងក្រោម :

- ភាគរយប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោត និងចូលរួមបោះឆ្នោត
- កម្រិតយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ
- កម្រិតគណនេយ្យភាពរបស់ឃុំ សង្កាត់ចំពោះប្រជាពលរដ្ឋ
- កម្រិតនៃការទទួលបានព័ត៌មាន
- កម្រិតនៃការបញ្ចេញមតិយោបល់របស់ប្រជាពលរដ្ឋ
- សមភាពនៃការទទួលបានសេវាសង្គមនានារបស់ប្រជាពលរដ្ឋ
- ចំនួនគ្រួសារកើតមានអំពើហិង្សាក្នុងគ្រួសារ ។

### ង). សកម្មភាពឃុំ សង្កាត់ក្នុងការលើកកម្ពស់សិទ្ធិសេរីភាព

ក្រុមប្រឹក្សាឃុំ សង្កាត់លើកកម្ពស់សិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់ តាមរយៈ :

- ការលើកទឹកចិត្តប្រជាពលរដ្ឋឱ្យទៅចុះឈ្មោះបោះឆ្នោត និងទៅបោះឆ្នោះជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងតំណាងរាស្ត្រ
- ការផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងកុមារ សមភាពយេនឌ័រ ការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការលុបបំបាត់ការរើសអើងស្ត្រី
- ការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការងារអភិវឌ្ឍន៍ និងការគ្រប់គ្រងឃុំ សង្កាត់ដល់ប្រជាពលរដ្ឋ

- ការលើកទឹកចិត្តប្រជាពលរដ្ឋចូលរួមផ្តល់យោបល់ក្នុងការងារអភិវឌ្ឍន៍ និងគ្រប់គ្រងឃុំ សង្កាត់
- ការលើកកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមសកម្មភាពនយោបាយ ជំនឿសាសនា ប្រពៃណី និងទំនៀមទម្លាប់
- ការសិក្សាផលប៉ះពាល់ដីធ្លី បរិស្ថាន និងជនជាតិដើមភាគតិចរាល់គម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ ដើម្បីពិភាក្សាជាមួយប្រជាពលរដ្ឋក្នុងការស្វែងរកដំណោះស្រាយសមស្រប ។

## ២.៤. ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

### ក). ធនធានធម្មជាតិ

### ក.១). និយមន័យនៃធនធានធម្មជាតិ

ធនធានធម្មជាតិ សំដៅលើធនធានដែលកើតឡើងដោយធម្មជាតិ ដូចជា ដី ភ្នំ ទន្លេ បឹងបួ រ៉ែ ព្រៃព្រឹក្សា និងសត្វព្រៃ ។ល។ ជាទូទៅ ធនធានធម្មជាតិត្រូវបានចែកចេញជាពីរប្រភេទគឺ ធនធានធម្មជាតិកកើតឡើងវិញ និងធនធានធម្មជាតិមិនអាចកកើតឡើងវិញ ។

### ក.២). ធនធានធម្មជាតិកកើតឡើងវិញ

ធនធានធម្មជាតិកកើតឡើងវិញ គឺជាធនធានធម្មជាតិទាំងឡាយណាដែលអាចប្រើប្រាស់ និងគ្រប់គ្រងបានដោយនិរន្តរភាព ។ ធនធានធម្មជាតិទាំងនេះអាចកកើតចេញពីប្រភពដែលមិនចេះរីងស្ងួត ដូចជា ថាមពលព្រះអាទិត្យ ថាមពលខ្យល់ ទឹក ដី ព្រៃឈើ និងសត្វ ។ល។ សុទ្ធតែកើតឡើងវិញ ឬអាចកើតឡើងវិញ ។

### ក.៣). ធនធានធម្មជាតិមិនអាចកកើតឡើងវិញ

ធនធានធម្មជាតិមិនអាចកកើតឡើងវិញ គឺជាធនធានធម្មជាតិទាំងឡាយណាដែលអាចប្រើប្រាស់អស់ទាំងស្រុង ឬអាចប្រើប្រាស់រហូតដល់កម្រិតមួយដែលមិនអាចទាញយកមកប្រើប្រាស់ទៀតបាន ដោយហេតុផលសេដ្ឋកិច្ច។ ធនធានធានធម្មជាតិមិនអាចកកើតឡើងវិញមានដូចជា ថ្ម ខ្សាច់ រ៉ែលោហៈ ឥន្ធនៈផូស៊ីល (ប្រេងកាត ឧស្ម័នធម្មជាតិ និងធ្យូងថ្ម) ត្រូវបានចាត់ទុកជាធនធានធម្មជាតិមិនអាចកកើតឡើងវិញ ដោយសារវាកកើតឡើងយឺតក្នុងរយៈពេលរាប់លានឆ្នាំ។

ធនធានធម្មជាតិជាច្រើនទាំងកកើតឡើងវិញ និងមិនអាចកកើតឡើងវិញអាចត្រូវបានគេបង្កើត ឬប្រើប្រាស់វត្ថុផ្សេងជំនួសបាន ដូចជា ប្រេងកាតសម្រាប់ផលិតថាមពលអគ្គីសនីអាចជំនួសដោយថាមពលខ្យល់ ឬពន្លឺព្រះអាទិត្យ។ ចំពោះធនធានធម្មជាតិខ្លះទៀតពុំអាចជំនួស ឬបង្កើតបានឡើយ ដូចជា ប្រភេទសត្វ និងរុក្ខជាតិដែលបានវិនាសសាបសូន្យ។

### ក.៤). ការគ្រប់គ្រងធនធានធម្មជាតិ

ការគ្រប់គ្រងធនធានធម្មជាតិ គឺជាការថែរក្សា និងការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងឃុំ សង្កាត់ ដើម្បីឆ្លើយតបតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងធានាបាននិរន្តរភាពធនធានធម្មជាតិ។

ធនធានធម្មជាតិដែលប្រជាពលរដ្ឋប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃមានៈ

- **ដីធ្លី** : ធ្វើស្រែចំការ លំនៅដ្ឋាន ផ្លូវថ្នល់ សាលារៀន និងមណ្ឌលសុខភាព។ល។

- **ទឹកទន្លេ បឹងបួ :** ស្រោចស្រពស្រូវ ដំណាំ បរិភោគ ចិញ្ចឹមត្រី និងសត្វពាហនៈ ។ល។
- **ព្រៃឈើ :** បម្រើផ្នែកសេដ្ឋកិច្ច និងអភិរក្សផ្នែកបរិស្ថាន។

នៅក្នុងមេរៀននេះ ផ្នែកធនធានធម្មជាតិ ផ្តោតសំខាន់លើការបង្ហាញអំពីធនធានព្រៃឈើ។

**ក.៥). សារប្រយោជន៍នៃព្រៃឈើចំពោះប្រជាពលរដ្ឋនៅមូលដ្ឋាន**

ព្រៃឈើមានសារប្រយោជន៍ចំពោះប្រជាពលរដ្ឋនៅមូលដ្ឋានដូចខាងក្រោម :

- **ផ្នែកសេដ្ឋកិច្ច :**
  - ផ្តល់អុសជាថាមពលសម្រាប់ចម្អិនអាហារ
  - ឈើសម្រាប់សំណង់ គ្រឿងសង្ហារឹម ឧបករណ៍កសិកម្ម
  - ផលិតផ្សេងៗ : អាហារ ឱសថ ជ័រ និងល័ក្ខ
  - ទេសចរណ៍ធម្មជាតិ : ទេសភាព សត្វ ព្រៃព្រឹក្សា ជ្រោះ ។ល។
- **ផ្នែកបរិស្ថាន :**
  - ការពារការហូរច្រោះដី និងការពារប្រភពទឹក
  - ជំរកសត្វព្រៃ និងមច្ឆជាតិ
  - បង្កើនជីវជាតិដី
  - ស្រូបកំដៅព្រះអាទិត្យ
  - ការពារខ្យល់ព្យុះ
  - លំនឹងបរិស្ថានទាំងអាកាសធាតុ និងជីវសាស្ត្រ

## ក.៦). សូចនាករមួយចំនួនបង្ហាញអំពីធនធានព្រៃឈើ

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពធនធានព្រៃឈើនៅឃុំ សង្កាត់ មានដូចខាងក្រោម :

- ចំនួនដីព្រៃដែលបាត់បង់ដោយសារការរានដីព្រៃ
- កម្រិតគម្របព្រៃឈើ
- ចំនួនផ្ទៃដីដែលបានដាំដុះដើមឈើឡើងវិញ
- កម្រិតនៃការប្រើប្រាស់ធនធានព្រៃឈើ
- ចំនួនផ្ទៃដីព្រៃដែលទទួលរងភ្លើងឆេះប្រចាំឆ្នាំ។

## ក.៧).សកម្មភាពឃុំ សង្កាត់ក្នុងការគ្រប់គ្រងធនធានព្រៃឈើ

ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋចូលរួមគ្រប់គ្រងធនធានព្រៃឈើនៅក្នុងឃុំ សង្កាត់ តាមរយៈ :

- ការរៀបចំបង្កើតសហគមន៍ព្រៃឈើក្នុងការគ្រប់គ្រងព្រៃឈើ
- ការទប់ស្កាត់រាល់ការរានដីព្រៃ និងការកាប់បំផ្លាញព្រៃឈើ
- ការការពារ និងទប់ស្កាត់ភ្លើងឆេះព្រៃ
- ការអប់រំផ្សព្វផ្សាយប្រជាពលរដ្ឋឱ្យចូលរួមថែរក្សាព្រៃឈើ
- ការប្រើប្រាស់ចង្ក្រានប្រសិទ្ធភាព និងជីវឧស្ម័ន ដើម្បីជួយកាត់បន្ថយការប្រើប្រាស់ធនធានព្រៃឈើ
- ការរៀបចំតំបន់ទេសចរណ៍ធម្មជាតិ
- . . .។ល។

## ១). បរិស្ថាន

### ១.១). និយមន័យនៃបរិស្ថាន

បរិស្ថាន គឺជាអ្វីៗដែលនៅជុំវិញខ្លួនយើង ទាំងភាវៈមានជីវិត និងភាវៈគ្មានជីវិត ហើយមានទំនាក់ទំនង និងមានឥទ្ធិពលដោយផ្ទាល់ ឬដោយប្រយោលទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ។

- ភាវៈមានជីវិតមានរុក្ខជាតិ ព្រៃព្រឹក្សា សត្វ
- ភាវៈគ្មានជីវិតមានដី ទឹក ពន្លឺ ភ្លៀង ខ្យល់
- ឥទ្ធិពលដោយផ្ទាល់មានខ្យល់ព្យុះ ទឹកភ្លៀង( រាំងស្ងួត ទឹកជំនន់)
- ឥទ្ធិពលដោយប្រយោលមានការបាត់បង់រុក្ខជាតិ ឬពូជសត្វព្រៃមួយចំនួន ។

### ១.២). ការថែរក្សាបរិស្ថាន

ការថែរក្សាបរិស្ថាន សំដៅលើការគ្រប់គ្រងសកម្មភាពមនុស្ស ដើម្បីជៀសវាងបាននូវការផ្លាស់ប្តូរលក្ខណៈរូបសាស្ត្រ (ទឹក ដី ខ្យល់ អាកាសធាតុ) លក្ខណៈជីវសាស្ត្រ (រុក្ខជាតិ និងសត្វ) និងមជ្ឈដ្ឋាន ឬជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។ ការថែរក្សាបរិស្ថានអាចធ្វើឱ្យបរិស្ថានមានលំនឹង ដើម្បីជួយទ្រទ្រង់ជីវិតមនុស្ស និងសត្វ ។

### ១.៣). សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពបរិស្ថាន

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពបរិស្ថាននៅឃុំ សង្កាត់មានដូចជា :

- ចំនួនគ្រួសារដែលប្រើថ្នាំគីមីសម្រាប់ការដាំដំណាំ
- ចំនួនផ្ទះដែលមានអ្នកប្រមូលសំរាមទៅចោលនៅទីតាំងកំណត់
- ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់
- ចំនួនផ្ទៃដីដែលបានដាំដុះដើមឈើឡើងវិញ
- ចំនួនផ្ទៃដីព្រៃដែលទទួលរងភ្លើងឆេះប្រចាំឆ្នាំ
- ចំនួនគ្រួសារដែលរងគ្រោះដោយធម្មជាតិ ។

### ១.៤). សកម្មភាពឃុំ សង្កាត់ក្នុងការថែរក្សាបរិស្ថាន

ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋចូលរួមថែរក្សាបរិស្ថាននៅក្នុងឃុំ សង្កាត់ តាមរយៈ :

- ការគ្រប់គ្រង ការការពារព្រៃឈើ និងការដាំដើមឈើឡើងវិញ
- ការទប់ស្កាត់ការដុតបំផ្លាញព្រៃឈើ និងការរានដីព្រៃ
- ការអប់រំប្រជាពលរដ្ឋក្នុងការចូលរួមថែរក្សា និងគ្រប់គ្រងព្រៃឈើ
- ការសិក្សាផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់
- ការទុកដាក់សំរាម និងការចោលសំរាមឱ្យបានត្រឹមត្រូវ ។

## ២.៥. ការកសាងហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ ជាធនធានមួយយ៉ាងសំខាន់ជួយជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់ស្ថានភាពសង្គម និងកែលម្អបរិស្ថាន ។

### ក). សារប្រយោជន៍នៃហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធអាចបម្រើសេចក្តីត្រូវការដូចខាងក្រោម :

- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យសេដ្ឋកិច្ច : ប្រព័ន្ធធារាសាស្ត្រ បណ្តាញអគ្គីសនី ប្រព័ន្ធគមនាគមន៍ ផ្សារសហគមន៍ ។ល ។
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យសង្គម : លំនៅដ្ឋាន សាលាឃុំ សង្កាត់ សាលារៀន មណ្ឌលសុខភាព វត្តអារាម បណ្តាញទឹកស្អាត អណ្តូងទឹក និងស្រះទឹក ។ល ។
- ហេដ្ឋារចនាសម្ព័ន្ធបម្រើឱ្យវិស័យបរិស្ថាន : ទំនប់ការពារទឹកជំនន់ ទីទួលសុវត្ថិភាព ប្រឡាយ ឬលូបង្ហូរទឹកសំណល់ និងទីកន្លែងចាក់សំរាម ។ល ។

ហេដ្ឋារចនាសម្ព័ន្ធមួយចំនួនអាចបម្រើឱ្យវិស័យមួយជាក់លាក់ដូចជា សាលារៀន មន្ទីរពេទ្យ ទីកន្លែងចាក់សំរាម និងស្ថានីយ៍បូមទឹក ។ល ។ ប៉ុន្តែ ហេដ្ឋារចនាសម្ព័ន្ធមួយចំនួនក៏អាចបម្រើឱ្យវិស័យជាច្រើនដូចជា ផ្លូវថ្នល់អាចសម្រួលដល់ការដឹកកសិផលទៅកាន់ទីផ្សារ ក៏អាចសម្រួលដល់ការធ្វើដំណើរទៅកាន់មណ្ឌលសុខភាព និងសាលារៀន ។ល ។

### ខ). សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពហេដ្ឋារចនាសម្ព័ន្ធនៅឃុំ សង្កាត់មានដូចជា :

- ប្រវែងផ្លូវថ្នល់ និងប្រភេទផ្លូវថ្នល់
- ប្រវែងប្រឡាយ និងប្រភេទប្រឡាយ
- ចំនួនស្ពាន និងប្រភេទស្ពាន

- ចំនួនលូបង្ហូរទឹក និងប្រភេទលូបង្ហូរទឹក
- បណ្តាញអគ្គិសនី
- ប្រភេទលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ
- ចំនួនអគារសាធារណៈ មន្ទីរពេទ្យ សាលារៀន
- . . . ។ល។

## គ). សកម្មភាពឃុំ សង្កាត់ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ

ក្រុមប្រឹក្សាឃុំ សង្កាត់សាងសង់ហេដ្ឋារចនាសម្ព័ន្ធក្នុងឃុំ សង្កាត់របស់ខ្លួនដូចជា :

- សាងសង់ប្រព័ន្ធគមនាគមន៍ : ផ្លូវថ្នល់ ស្ពាន និងលូបង្ហូរទឹក
- សាងសង់ប្រព័ន្ធធារាសាស្ត្រ : ប្រឡាយ ទំនប់ និងស្ថានីយបូមទឹក
- សាងសង់មណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព
- សាងសង់អគារសិក្សា
- សង់ទីទួលសុវត្ថិភាព និងទំនប់ការពារទឹកជំនន់
- . . . ។ល។

## ២.៦. ការអភិវឌ្ឍស្ថាប័ន

ស្ថាប័ន គឺជាអង្គការចាត់តាំងមួយដែលមានយន្តការ និងរចនាសម្ព័ន្ធគ្រប់គ្រង ដើម្បីចាត់ចែង និងតម្រង់ទិសការអនុវត្តរបស់សមាជិកក្នុងស្ថាប័នឱ្យបំពេញការងារស្របតាមគោលបំណង ។

## ក). សមាសភាគរបស់ស្ថាប័នដែលត្រូវអភិវឌ្ឍន៍

ការអភិវឌ្ឍស្ថាប័ន គឺជាការធ្វើឱ្យប្រសើរឡើងដល់យន្តការគ្រប់គ្រង និងបង្កើនសមត្ថភាពបុគ្គលិក ដើម្បីធ្វើឱ្យការអនុវត្តមុខងាររបស់ស្ថាប័នប្រកបដោយប្រសិទ្ធភាព ។

ការអភិវឌ្ឍស្ថាប័នត្រូវពិនិត្យលើសមាសភាគដូចខាងក្រោម :

- **ស្ថាប័ន :** ច្បាប់ បទដ្ឋានការងារ សិទ្ធិអំណាច និងរចនាសម្ព័ន្ធ
- **គ្រប់គ្រង :** ប្រព័ន្ធការងារ នីតិវិធី វិន័យ
- **បុគ្គលិក :** ចំនួនបុគ្គលិក និងសមត្ថភាពរបស់បុគ្គលិក

## ខ). សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពគ្រប់គ្រងស្ថាប័ន

សូចនាករមួយចំនួនបង្ហាញអំពីស្ថានភាពគ្រប់គ្រងស្ថាប័នមានដូចខាងក្រោម :

- រចនាសម្ព័ន្ធគ្រប់គ្រងរបស់ស្ថាប័ន
- ការកំណត់តួនាទី និងភារកិច្ចរបស់ស្ថាប័ន និងបុគ្គលិក
- គោលការណ៍គ្រប់គ្រងរបស់ស្ថាប័ន
- ចំនួន និងសមត្ថភាពបុគ្គលិក (ចំណេះដឹង ជំនាញ និងឥរិយាបថ)
- គុណភាពនៃការផ្តល់សេវា និងការឆ្លើយតប
- គណនេយ្យភាព និងតម្លាភាព ។

## គ). ការពង្រឹងស្ថាប័ន

### គ.១). ការកសាងធនធានមនុស្ស

ការកសាងធនធានមនុស្សជាមូលដ្ឋានគ្រឹះក្នុងការបង្កើនប្រសិទ្ធភាពគ្រប់គ្រង ។ ការកសាងធនធានមនុស្សត្រូវផ្ដោតការយកចិត្តទុកដាក់លើ :

- ចំនួនបុគ្គលិក
- ជំនាញរបស់បុគ្គលិកឱ្យស្របតាមក្របខ័ណ្ឌការងាររបស់ស្ថាប័ន
- តម្រូវការសមត្ថភាពរបស់បុគ្គលិកទៅតាមតួនាទី និងមុខងារ ។

ក្រុមប្រឹក្សាឃុំ សង្កាត់កសាងសមត្ថភាពរបស់ខ្លួន ដូចជា :

- ចូលរួមវគ្គបណ្ដុះបណ្ដាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា
- រៀនសូត្រពីការអនុវត្តជាក់ស្ដែង
- ផ្លាស់ប្ដូរ និងចែករំលែកព័ត៌មាន និងការឆ្លុះបញ្ចាំងកែលម្អ

### គ.២). ការគ្រប់គ្រងទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិសំដៅលើធនធាននានាសម្រាប់បម្រើសេចក្ដីត្រូវការក្នុងការបំពេញការងាររបស់បុគ្គលិក និងស្ថាប័ន ។

ដើម្បីបំពេញការងារបានសមស្រប ឃុំ សង្កាត់ត្រូវមានទ្រព្យសម្បត្តិមួយចំនួនដូចខាងក្រោម :

- អចលនវត្ថុ : ដីធ្លី និងអគារសាលាឃុំ សង្កាត់ ។ល ។
- ចលនវត្ថុ : ម៉ូតូ កង់ វិទ្យុទាក់ទង និងម៉ាស៊ីនភ្លើង ។ល ។
- សម្ភារការិយាល័យ : តុកៅអី កុំព្យូទ័រ និងទូដាក់ឯកសារ ។ល ។

ដើម្បីគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិ ឃុំ សង្កាត់ត្រូវ :

- រៀបចំទុកដាក់ទ្រព្យសម្បត្តិ និងសម្ភារៈប្រើប្រាស់ឱ្យបានត្រឹមត្រូវ
- ចាត់ឱ្យមានអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រង និងថែរក្សាទ្រព្យសម្បត្តិ និងសម្ភារៈ
- កត់ត្រា និងរៀបចំបញ្ជីសារពើភ័ណ្ឌ ។

## ឃ). ការគ្រប់គ្រងហិរញ្ញវត្ថុ

ធនធានហិរញ្ញវត្ថុត្រូវបានប្រើប្រាស់សម្រាប់គាំទ្រការងារប្រតិបត្តិការរដ្ឋបាល និងការអភិវឌ្ឍ ដើម្បីឆ្លើយតបនឹងតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។ ការគ្រប់គ្រងហិរញ្ញវត្ថុត្រូវមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព ដោយផ្អែកទៅតាមនីតិវិធី និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ។

ឃុំ សង្កាត់គ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់តាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងនីតិវិធីដូចខាងក្រោម :

- រៀបចំថវិកាប្រចាំឆ្នាំ
- ប្រព័ន្ធគណនេយ្យ និងប្រព័ន្ធទូទាត់សម្រាប់ឃុំ សង្កាត់
- ការគ្រប់គ្រងចំណាយរបស់ឃុំ សង្កាត់
- រាល់ការចំណាយទាំងអស់ត្រូវធ្វើកិច្ចបញ្ជីកា
- សវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅ និង
- របាយការណ៍ហិរញ្ញវត្ថុឃុំ សង្កាត់ ។

### ង). ការគ្រប់គ្រងបុគ្គលិក

ការគ្រប់គ្រងបុគ្គលិក គឺជាដំណើរការនៃការចាត់ចែងការអនុវត្តការងារប្រចាំថ្ងៃ ដើម្បីឱ្យបុគ្គលិកបំពេញការងារប្រកបដោយប្រសិទ្ធភាព ។

ក្រុមប្រឹក្សាឃុំ សង្កាត់អាចគ្រប់គ្រងបុគ្គលិករបស់ខ្លួន តាមរយៈ :

- ការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ការកំណត់តួនាទី និងភារកិច្ចរបស់បុគ្គលិក ឬគណៈកម្មាធិការនានា
- រៀបចំផែនការការងារ និងរបាយការណ៍ការងារ
- តាមដានត្រួតពិនិត្យសកម្មភាព និងលទ្ធផលនៃការអនុវត្ត ។

### ច). ការប្រាស្រ័យទាក់ទង

ការប្រាស្រ័យទាក់ទង គឺជាលំហូរ ឬដំណើរការបញ្ជូនព័ត៌មាននៅក្នុងស្ថាប័ន ។ ការប្រាស្រ័យទាក់ទងល្អអាចជួយបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង ។

ក្រុមប្រឹក្សាឃុំ សង្កាត់ប្រាស្រ័យទាក់ទងជាមួយបុគ្គលិកឃុំ សង្កាត់ និងប្រជាពលរដ្ឋ តាមរយៈ :

- ការប្រជុំ
- ការពិគ្រោះយោបល់ ឬការជួបពិភាក្សាដោយផ្ទាល់
- ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មានឃុំ សង្កាត់
- ប្រអប់សំបុត្រគណនេយ្យភាព
- វិទ្យុទាក់ទង និងប្រព័ន្ធទូរស័ព្ទ ។

## ឃ). ការត្រួតពិនិត្យកិច្ចការបុគ្គលិក

ការត្រួតពិនិត្យកិច្ចការបុគ្គលិក ជាកិច្ចការមួយសំខាន់ជួយតម្រង់ទិសដល់ការអនុវត្តសកម្មភាព និងការបំពេញមុខងាររបស់បុគ្គលិកបានទាន់ពេលវេលា។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រួតពិនិត្យកិច្ចការបុគ្គលិកនៅឃុំ សង្កាត់តាមរយៈ :

- ផែនការសកម្មភាព
- ការពិនិត្យអំពីសកម្មភាព និងលទ្ធផលការងារ
- ការធ្វើសេចក្តីរាយការណ៍ក្នុងកិច្ចប្រជុំ
- ការរាយការណ៍ដោយផ្ទាល់
- របាយការណ៍សកម្មភាព និងលទ្ធផលការងារ។

# ៣. បែបបទនៃការអភិវឌ្ឍ

ការអភិវឌ្ឍអាចអនុវត្តន៍តាមបែបបទមួយចំនួនដូចខាងក្រោម :

- បែបបទអភិវឌ្ឍន៍តាមវិស័យ
- បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន
- បែបបទអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ

## ៣.១. បែបបទអភិវឌ្ឍន៍តាមវិស័យ

បែបបទអភិវឌ្ឍន៍តាមវិស័យ គឺជាដំណើរការអភិវឌ្ឍដែលផ្តោតលើវិស័យជាក់លាក់មួយកំណត់ ដូចជា វិស័យសុខាភិបាល វិស័យអប់រំ វិស័យកសិកម្ម វិស័យព្រៃឈើ និងវិស័យបរិស្ថាន ។ល។

មន្ទីរជំនាញរាជធានី ខេត្ត ធ្វើការអភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់តាមវិស័យរបស់ខ្លួន ដូចជា :

- មន្ទីរអប់រំ យុវជន និងកីឡា អភិវឌ្ឍន៍វិស័យអប់រំ និងកីឡា
- មន្ទីរសុខាភិបាល អភិវឌ្ឍន៍វិស័យសុខាភិបាល
- មន្ទីរកសិកម្ម អភិវឌ្ឍន៍វិស័យកសិកម្ម
- មន្ទីរកិច្ចការនារី អភិវឌ្ឍន៍វិស័យយេនឌ័រ

សារប្រយោជន៍នៃបែបបទអភិវឌ្ឍន៍តាមវិស័យ គឺ :

- ងាយស្រួលឆ្លើយតបនឹងគោលនយោបាយរបស់រដ្ឋាភិបាល
- ងាយនឹងសម្រេចតាមគោលដៅរបស់មន្ទីរ ឬស្ថាប័ន
- អនុវត្តតាមមុខងារ ឬបេសកកម្មជាក់លាក់របស់ស្ថាប័ន

- ដំណើរការអនុវត្តផ្អែកលើមូលដ្ឋានបច្ចេកទេស
- ងាយស្រួលបង្ហាញលទ្ធផលដែលសម្រេចបាន។

## ៣.២. បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន គឺជាដំណើរការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច ឈរលើគោលការណ៍លើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋានស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងកិច្ចការពារសិទ្ធិមនុស្ស។ គោលបំណង និងលទ្ធផលនៃការអភិវឌ្ឍ គឺធ្វើឱ្យសម្រេចបានការលើកកម្ពស់សិទ្ធិមនុស្សជាមូលដ្ឋាន។

បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋានមានធាតុសំខាន់ៗដូចខាងក្រោម :

- ការចូលរួមក្នុងការគ្រប់គ្រង និងសិទ្ធិនៃការចូលរួម
- ការលើកកម្ពស់ទាំងផ្នែកសេដ្ឋកិច្ច និងផ្នែកសង្គម
- មានគណនេយ្យភាពទៅវិញទៅមករវាងអាជ្ញាធរមានសមត្ថកិច្ច និងប្រជាពលរដ្ឋ ដោយគោរពសិទ្ធិ និងការទទួលខុសត្រូវ
- មានការគិតគូរគ្រប់ជ្រុងជ្រោយ ក្នុងការដោះស្រាយបញ្ហានានា ដើម្បីបង្កើតឱកាស និងជម្រើសនានាសម្រាប់លើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋានបានដាក់បញ្ចូលច្បាប់ លិខិតបទដ្ឋាន និងគោលការណ៍សិទ្ធិមនុស្សទៅក្នុងផែនការអភិវឌ្ឍន៍ គោលនយោបាយ និងដំណើរការអភិវឌ្ឍន៍។

### ក). ទស្សនៈនៃបែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

ទស្សនៈនៃបែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋានមានដូចជា :

- គិតពីផលប្រយោជន៍របស់ប្រជាពលរដ្ឋជាមូលដ្ឋាន
- ការសម្រេចចិត្តនានាត្រូវមានការចូលរួមពីប្រជាពលរដ្ឋ
- យល់ដឹងអំពីទំនាក់ទំនងរវាងសិទ្ធិ និងភាពក្រីក្រ
- ការចូលរួមរបស់ប្រជាពលរដ្ឋប្រកបដោយសមភាព
- លើកទឹកចិត្តដល់ប្រជាពលរដ្ឋក្រីក្រ ក្នុងការចរចាជាមួយអ្នកពាក់ព័ន្ធ
- អ្នកពាក់ព័ន្ធទាំងអស់ត្រូវមានគណនេយ្យភាព និងការទទួលខុសត្រូវទៅវិញទៅមក
- ទទួលស្គាល់ពីកាតព្វកិច្ចរបស់រដ្ឋ គឺសម្របសម្រួល និងលើកកម្ពស់សិទ្ធិរបស់ប្រជាពលរដ្ឋពិតប្រាកដ ។

### ខ). គោលការណ៍នៃបែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន

បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋានមានគោលការណ៍ដូចខាងក្រោម :

- ការអភិវឌ្ឍត្រូវធានាឱ្យបាននូវការគោរពសិទ្ធិមនុស្ស
- មានគណនេយ្យភាព
- ផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋ
- មានការចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍
- គ្មានការរើសអើង និងយកចិត្តទុកដាក់ដល់ជនងាយរងគ្រោះ

## ខ.១). ការអភិវឌ្ឍធានាឱ្យបាននូវការគោរពសិទ្ធិមនុស្ស

ការអភិវឌ្ឍធានាបាននូវការគោរពសិទ្ធិមនុស្សត្រូវយកចិត្តទុកដាក់ខ្លាំងទៅលើសិទ្ធិរបស់អ្នកពាក់ព័ន្ធមាន សិទ្ធិពលរដ្ឋ វប្បធម៌ សេដ្ឋកិច្ច នយោបាយ និងសង្គម ដោយធានាឱ្យបានសិទ្ធិជាមូលដ្ឋាន ដូចជា សិទ្ធិទទួលបានការថែទាំសុខភាព ការអប់រំ លំនៅដ្ឋាន យុត្តិធម៌ និងសិទ្ធិចូលរួមសកម្មភាពនយោបាយ។

ការអភិវឌ្ឍឃុំ សង្កាត់បានធានាដល់ការគោរពសិទ្ធិមនុស្សមានដូចជា :

- គម្រោងមូលនិធិឃុំ សង្កាត់ទាំងអស់ត្រូវបានសិក្សាផលប៉ះពាល់ដីធ្លី បរិស្ថាន និងជនជាតិដើមភាគតិច ដើម្បីធានាថារាល់ផលប៉ះពាល់ត្រូវបានពិភាក្សា និងដោះស្រាយជាមួយអ្នកពាក់ព័ន្ធប្រកបដោយសមភាព តម្លាភាព និងយុត្តិធម៌
- ការសាងសង់មណ្ឌលសុខភាព និងសាលារៀនត្រូវបានបម្រើឱ្យប្រជាពលរដ្ឋទូទៅក្នុងឃុំ សង្កាត់ ទាំងអ្នកមាន អ្នកក្រីក្រ ជនជាតិដើមភាគតិច ទាំងបុរស និងស្ត្រី មានសិទ្ធិស្មើភាពគ្នាក្នុងការទទួលសេវាទាំងនោះ។

## ខ.២).គណនេយ្យភាព

គណនេយ្យភាព មានន័យថា ការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការ និងអនុវត្តសេចក្តីសំរេចចិត្ត ហើយទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ដោយរាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត។

ប្រភេទនៃគណនេយ្យភាពមានដូចខាងក្រោម :

- **គណនេយ្យភាពចំពោះផ្នែកនយោបាយ** : គឺជាការទទួលខុសត្រូវរបស់មេឃុំ ចៅសង្កាត់ និងបុគ្គលិកឃុំ សង្កាត់ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់
- **គណនេយ្យភាពនៃក្រមសីលធម៌** : គឺជាការទទួលខុសត្រូវរបស់បុគ្គល និងការអនុវត្តរបស់រដ្ឋបាលឃុំ សង្កាត់ ក្នុងការលើកកម្ពស់ការបំពេញការងារ និងការបង្កើតបរិយាកាសការងារឱ្យបានល្អប្រសើរ
- **គណនេយ្យភាពនៃការគ្រប់គ្រងរដ្ឋបាល** : គឺជាការទទួលខុសត្រូវរបស់បុគ្គល និងការអនុវត្តរបស់រដ្ឋបាលឃុំ សង្កាត់ ដោយផ្អែកលើបញ្ហាផ្ទៃក្នុង និងគោលការណ៍នានា ដែលជាយន្តការ ដើម្បីឱ្យបុគ្គល និងរដ្ឋបាលឃុំ សង្កាត់យកទៅអនុវត្ត
- **គណនេយ្យភាពចំពោះប្រជាពលរដ្ឋ** : គឺជាការទទួលខុសត្រូវរបស់បុគ្គល និងរដ្ឋបាលឃុំ សង្កាត់ ក្នុងការទទួលយកមតិយោបល់ និងការឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ ដើម្បីជាមូលដ្ឋានក្នុងការសម្រេចចិត្តរបស់ឃុំ សង្កាត់។

បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋានផ្ដោតសំខាន់លើ :

- ការលើកកម្ពស់ការអនុវត្តសិទ្ធិស្មើភាពទាំងប្រជាពលរដ្ឋដែលជាអ្នកទទួលផល និងម្ចាស់គម្រោង

- ការផ្តល់ឱកាស និងលើកទឹកចិត្តឱ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដោយជៀសវាងរាល់សកម្មភាពនាំឱ្យរារាំង និងបំពានលើសិទ្ធិរបស់ប្រជាពលរដ្ឋ
- ការអនុវត្តសកម្មភាពស្របទៅនឹងច្បាប់ គោលនយោបាយ គោលការណ៍ នីតិវិធី និងយន្តការគ្រប់គ្រង ដើម្បីតម្រង់ទិសអនុវត្តឱ្យបានសមស្រប ។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងការងារអភិវឌ្ឍឃុំ សង្កាត់ ដោយ :

- កំណត់អំពីគម្រោងអាទិភាពដែលឆ្លើយតបនឹងតម្រូវការជាមូលដ្ឋានរបស់ប្រជាពលរដ្ឋទូទៅ
- អនុវត្តគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវអនុវត្តតាមគោលការណ៍ណែនាំ ដើម្បីធានាបានតម្លាភាព និងការចូលរួមរបស់ប្រជាពលរដ្ឋ
- ផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ អំពីសកម្មភាព និងលទ្ធផលនៃការអភិវឌ្ឍ និងការប្រើប្រាស់ធនធានរបស់ឃុំ សង្កាត់ ។

**១.៣). ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ**

ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ គឺជាការផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋក្នុងការចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត ដោយគ្មានការរើសអើង ។

បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋាន គឺជាយុទ្ធសាស្ត្រមួយ ក្នុងការផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋ ។ ការផ្តល់សិទ្ធិដល់ប្រជាពលរដ្ឋត្រូវចាត់ទុកប្រជាពលរដ្ឋដែលជាអ្នកទទួលផលជាម្ចាស់គម្រោង និងអាចចូលរួមគ្រប់គ្រងការងារអភិវឌ្ឍន៍ ។

គោលដៅនៃការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ គឺជាការផ្តល់ឱ្យប្រជាពលរដ្ឋនូវសិទ្ធិ សមត្ថភាព ភាពអង់អាច និងការទទួលបានផលប្រយោជន៍ ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរស្ថានភាពជីវភាពរស់នៅ និងស្ថានភាពសហគមន៍របស់ខ្លួន ដែលមានឥទ្ធិពលដល់វាសនារបស់ពួកគេ។

ការផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ លុះត្រាតែប្រជាពលរដ្ឋ :

- មានលទ្ធភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តជាលក្ខណៈបុគ្គល ឬជាសមូហភាព
- ទទួលបានព័ត៌មាន និងមធ្យោបាយនានា សម្រាប់ការធ្វើសេចក្តីសម្រេចចិត្ត
- មានសិទ្ធិក្នុងការគិតពិចារណា ដើម្បីជ្រើសរើសនូវជម្រើសនានានៃការធ្វើសេចក្តីសម្រេចចិត្ត
- មានសិទ្ធិការពារអំពីសេចក្តីសម្រេចរបស់ខ្លួន និងសមូហភាព
- មានសិទ្ធិផ្តល់គំនិតយោបល់ប្រកបដោយវិជ្ជមាន ដើម្បីកែលម្អធ្វើការសេចក្តីសម្រេចចិត្ត

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវលើកកម្ពស់សិទ្ធិប្រជាពលរដ្ឋចូលរួមក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ដោយធានាថា :

- ប្រជាពលរដ្ឋមានសិទ្ធិលើកឡើងអំពីតម្រូវការរបស់ខ្លួនក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ដើម្បីធ្វើសេចក្តីសម្រេចចិត្តអភិវឌ្ឍន៍ឃុំ សង្កាត់

- ប្រជាពលរដ្ឋមានសិទ្ធិចូលរួមក្នុងគណៈកម្មការគ្រប់គ្រងគម្រោង និងផ្តល់យោបល់នានាទាក់ទងនឹងការគ្រប់គ្រងការងារអភិវឌ្ឍន៍ឃុំ សង្កាត់
- ប្រជាពលរដ្ឋមានសិទ្ធិក្នុងការទទួលបានព័ត៌មាននានាទាក់ទងនឹងការគ្រប់គ្រង ការប្រើប្រាស់ថវិកា បញ្ហា និងដំណោះស្រាយនានាក្នុងការអភិវឌ្ឍឃុំ សង្កាត់។

## ១.៤). ការចូលរួមក្នុងសកម្មភាពអភិវឌ្ឍន៍

ការចូលរួម សំដៅទៅលើការចូលរួមរបស់ប្រជាពលរដ្ឋទាំង បុរស និងស្ត្រី ក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តនោះ។

សារៈសំខាន់នៃការចូលរួម គឺដើម្បីធានាថា ព័ត៌មានទាំងឡាយស្តីពីបញ្ហា តម្រូវការ និងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋគ្រប់រូបត្រូវបានប្រមូល និងវិភាគបានគ្រប់ជ្រុងជ្រោយ មុននឹងធ្វើការសម្រេចចិត្ត ។

ការចូលរួមក្នុងការសកម្មភាពអភិវឌ្ឍន៍អាចធ្វើឡើងតាមរយៈ :

- **ការចូលរួមដោយផ្ទាល់** : មានន័យថា ជាការចូលរួមរបស់អ្នកពាក់ព័ន្ធគ្រប់រូប ដោយខ្លួនឯងផ្ទាល់នៅក្នុងដំណើរនៃការធ្វើការសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តនោះ។
- **ការចូលរួមតាមរយៈអ្នកតំណាង** : មានន័យថា អ្នកតំណាងរបស់ប្រជាពលរដ្ឋចូលរួមក្នុងដំណើរការនៃការសំរេចចិត្ត និងអនុវត្តសេចក្តីសម្រេចនោះ។ អ្នកតំណាងត្រូវតែបំពេញតួនាទីជាអ្នកតំណាងឱ្យឆន្ទៈ និងផលប្រយោជន៍ប្រជាពលរដ្ឋដែលខ្លួនតំណាងឱ្យ

បែបបទអភិវឌ្ឍន៍ផ្អែកលើសិទ្ធិជាមូលដ្ឋានតម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីអ្នកពាក់ព័ន្ធទាំងអស់ ដូចជា ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន សង្គមស៊ីវិល ជនជាតិដើមភាគតិច បុរស និងស្ត្រី ។ ការចូលរួមក្នុងការអភិវឌ្ឍត្រូវចូលរួមដោយផ្ទាល់ ដោយសកម្ម ដោយសេរី និងប្រកបដោយអត្ថន័យ ។

ប្រជាពលរដ្ឋអាចចូលរួមក្នុងការងារអភិវឌ្ឍន៍ឃុំ សង្កាត់ ដូចជា :

- ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់
- ចូលរួមសិក្សាលទ្ធភាព និងផលប៉ះពាល់របស់គម្រោងលើបរិស្ថានដីធ្លី និងជនជាតិដើមភាគតិច
- ចូលរួមតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍន៍
- ចូលរួមគ្រប់គ្រង និងថែទាំសមិទ្ធផលរបស់គម្រោងនៅក្នុងឃុំ សង្កាត់ ។

### ១.៥). គ្មានការរើសអើង និងយកចិត្តទុកដាក់ដល់ជនងាយរងគ្រោះ

គ្មានការរើសអើង គឺជាអំពើដែលបង្ហាញអំពីការមិនប្រកាន់បក្សពួក ភាពមិនលម្អៀងទៅលើបុគ្គល ឬក្រុមណាមួយ ឬប្រកបដោយសមភាព ។

ការរើសអើងអាចកើតមានលើលក្ខណៈមួយចំនួនដូច អាយុ ភេទ ខាងផ្លូវកាយ ចំណេះដឹង សមត្ថភាព បទពិសោធន៍ ជាតិសាសន៍ និងសាសនា ។

ការរើសអើងមានទម្រង់ដូចខាងក្រោម :

- ការរើសអើងដោយផ្ទាល់ : រារាំងមិនឱ្យចូលរួមសកម្មភាពអភិវឌ្ឍន៍
- ការរើសអើងដោយប្រយោល : មិនផ្តល់ព័ត៌មានឱ្យបានគ្រប់គ្រាន់

បែបបទនៃការអភិវឌ្ឍផ្អែកលើសិទ្ធិជាមូលដ្ឋានត្រូវយកចិត្តទុកដាក់ជាពិសេស ចំពោះការរើសអើង សមភាព សមធម៌ និងជនងាយរងគ្រោះ ជនពិការ ស្ត្រី កុមារ ប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិច ។

វិធានការការពារនានាត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់ជួយដល់ដំណើរការនៃការអភិវឌ្ឍ ដើម្បីធានាបាននូវការលុបបំបាត់ភាពរើសអើង និងកិច្ចការពារសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ និងសុខុមាលភាពរបស់ជនជាតិដើមភាគតិច និងជនងាយរងគ្រោះ ។

ក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់ ឃុំ សង្កាត់បានប្រើប្រាស់ឧបករណ៍មួយចំនួន ដើម្បីលុបបំបាត់ការរើសអើង និងបង្កើនការយកចិត្តទុកដាក់ដល់ប្រជាពលរដ្ឋគ្រប់រូប ដូចជា :

- ឧបករណ៍ និងវិធីសាស្ត្រសម្រាប់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ក្នុងការបញ្ជ្រាបយេនឌ័រក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- គោលការណ៍ណែនាំនានាសម្រាប់ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ទាក់ទងនឹងបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដូចជា :
  - គោលការណ៍ណែនាំសម្រាប់វិភាគផលប៉ះពាល់បរិស្ថាន
  - គោលការណ៍ណែនាំសម្រាប់រៀបចំរបាយការណ៍សិក្សាដីធ្លី
  - គោលការណ៍ណែនាំ ស្តីពីសុវត្ថិភាពជនជាតិដើមភាគតិច ។

## ៣.៣. បែបបទអភិវឌ្ឍន៍តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ

### ក). វិមជ្ឈការ

### ក.១). និយមន័យនៃវិមជ្ឈការ

វិមជ្ឈការមានន័យថា រាជរដ្ឋាភិបាលប្រគល់ឱ្យក្រុមប្រឹក្សានូវភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់មូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។

### ក.២). សារប្រយោជន៍នៃវិមជ្ឈការ

- ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមយ៉ាងសកម្មក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន
- ពង្រឹង និងពង្រីកការចូលរួមជាសាធារណៈ នៅក្នុងការអភិវឌ្ឍ ដើម្បីឆ្លើយតបនឹងតម្រូវការ និងអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- ធ្វើឱ្យមានគណនេយ្យភាពនៅក្នុងវិស័យសាធារណៈ
- កាត់បន្ថយការិយាធិបតេយ្យនៅក្នុងរដ្ឋបាលសាធារណៈ
- បង្កើតសេវាសាធារណៈឱ្យជិតប្រជាពលរដ្ឋ។

### ក.៣). គោលដៅនៃវិមជ្ឈការ

- ពង្រឹងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅមូលដ្ឋាន
- លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច

- ជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ តាមរយៈការបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្ត។

**ក.៤). ទម្រង់នៃវិមជ្ឈការ**

វិមជ្ឈការមានទម្រង់ដូចខាងក្រោម :

- **វិមជ្ឈការរដ្ឋបាល** : ជាការផ្ទេរការទទួលខុសត្រូវក្នុងការរៀបចំផែនការ និងការគ្រប់គ្រងមុខងារសាធារណៈពីរដ្ឋាភិបាលថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ យោងតាមច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ :
    - ក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់ និងជួយកិច្ចការនានាតាមការចាំបាច់ (មាត្រា២៧)
    - ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន (មាត្រា៦០)
    - ក្រុមប្រឹក្សាឃុំ សង្កាត់នៅតែជាអ្នកទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យ និងវាយតម្លៃចំពោះផែនការ កម្មវិធី និងគម្រោងនានា ទោះជាការងារនោះត្រូវបានអនុវត្តដោយសមាសភាពណាក៏ដោយ ដែលខ្លួនបានជ្រើសយក (មាត្រា៦៧)។

- **វិមជ្ឈការហិរញ្ញវត្ថុ** ៖ ការអនុវត្តមុខងារវិមជ្ឈការហិរញ្ញវត្ថុមានប្រសិទ្ធភាព លុះត្រាតែរដ្ឋបាលមូលដ្ឋាននោះមានកម្រិតចំណូលគ្រប់គ្រាន់ ទោះជាចំណូលបានមកពីចំណូលនៅមូលដ្ឋាន ឬជា ចំណូលផ្ទេរពីរដ្ឋាភិបាលក៏ដោយ រួមទាំងសិទ្ធិអំណាចក្នុងការសម្រេចចិត្តប្រើប្រាស់មូលនិធិនោះផងដែរ។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ៖
  - ឃុំ សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់ (មាត្រា ៧៣)
  - ឃុំ សង្កាត់មានសិទ្ធិទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋសម្រាប់ថវិការបស់ខ្លួន(មាត្រា៧៥)
  - ឃុំ សង្កាត់នីមួយៗមានសិទ្ធិទទួលបាននូវកម្រៃចំពោះការអនុវត្តនូវមុខងារជាភ្នាក់ងារតំណាងរដ្ឋដែលរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យ (មាត្រា៧៦)។
- **វិមជ្ឈការនយោបាយ** ៖ ការអនុវត្តវិមជ្ឈការនយោបាយមានគោលបំណងផ្តល់អំណាចកាន់តែច្រើនក្នុងការធ្វើការសម្រេចចិត្តលើកិច្ចការសាធារណៈទៅឱ្យប្រជាពលរដ្ឋ ឬតំណាងប្រជាពលរដ្ឋដែលជ្រើសតាំងឡើងដោយការបោះឆ្នោត។ ការជ្រើសរើសតំណាងតាមការបោះឆ្នោតនៅមូលដ្ឋានធ្វើឱ្យប្រជាពលរដ្ឋយល់កាន់តែ

ច្បាស់អំពីតំណាងរបស់ខ្លួន ហើយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រជាពលរដ្ឋបានបោះឆ្នោតឱ្យក៏យល់អំពីតម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតផងដែរ។ យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ :

- ឃុំ សង្កាត់ជានីតិបុគ្គល ( មាត្រា២)
- អំណាចដឹកនាំ និងគ្រប់គ្រងឃុំ សង្កាត់បានមកដោយការបោះឆ្នោត ជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសម្ងាត់ក្នុងក្របខ័ណ្ឌនៃឃុំ សង្កាត់នីមួយៗ ( មាត្រា៤)
- ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ទូទៅក្នុងឃុំ សង្កាត់របស់ខ្លួន( មាត្រា៩)
- ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង( មាត្រា១១) ។

**ក.៥). សូចនាករមួយចំនួនបង្ហាញអំពីវិមជ្ឈការ**

- កម្រិតនៃការផ្តល់អំណាចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- កម្រិតនៃការសម្រេចចិត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មុខងារដែលផ្ទេរពីរដ្ឋាភិបាលទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

- សិទ្ធិក្នុងការប្រមូលចំណូល និងកម្រៃផ្សេងៗនៅមូលដ្ឋាន
- ការផ្តល់ឱ្យមូលដ្ឋាននូវប្រភពចំណូលផ្ទាល់
- កម្រិតស្វ័យភាពក្នុងការប្រើប្រាស់មូលនិធិ
- កម្រិតពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ
- ភាគរយប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោត និងចូលរួមបោះឆ្នោត។

## ខ). វិសហមជ្ឈការ

វិសហមជ្ឈការ គឺរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធានទៅអង្គភាពក្រោមបង្គាប់ ឬ ទៅក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន។ អង្គភាព ឬ ក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ឬ ក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។

យោងតាមច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានចែងថា :

- អភិបាលមានតួនាទីជាតំណាងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីណែនាំ សម្របសម្រួល តម្រង់ទិស មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាលដែលធ្វើសកម្មភាព ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល អភិបាលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា( មាត្រា ១៥៤) ។

ប្រតិភូកម្មមុខងារ គឺការផ្ទេរនូវមុខងារ ការទទួលខុសត្រូវ អំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកកិច្ចការដែលបានធ្វើប្រតិភូកម្ម ។

យោងតាមច្បាប់ ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានចែងថា :

- ក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំ ចៅសង្កាត់នៅតែទទួលខុសត្រូវលើកិច្ចការដែលបានធ្វើប្រតិភូកម្មនោះ ( មាត្រា៥២)

### គ). ភាពខុសគ្នារវាងវិមជ្ឈការ និងវិសហមជ្ឈការ

វិមជ្ឈការ និងវិសហមជ្ឈការមានភាពខុសគ្នាដូចខាងក្រោម :

| វិមជ្ឈការ | វិសហមជ្ឈការ |
|---|---|
| - គោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ និងអភិបាលកិច្ចល្អនៅថ្នាក់រដ្ឋបាលក្រោមជាតិ | - គោលបំណង ដើម្បីបង្កើតការទទួលខុសត្រូវរបស់រដ្ឋ ក្នុងការផ្តល់សេវាសាធារណៈ ដល់ប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាព |
| - អង្គភាពអនុវត្តជាអង្គភាពនីតិបុគ្គលដាច់ដោយឡែក | - អង្គភាពអនុវត្តមិនមែនជា នីតិបុគ្គល ដោយឡែកពីថ្នាក់ជាតិ |
| - តំណាងកើតចេញពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ | - មន្ត្រីអនុវត្តកើតចេញពីការតែងតាំង |
| - តំណាងឱ្យអ្នកបោះឆ្នោត | - តំណាងឱ្យថ្នាក់ជាតិ |

៣. បែបបទនៃការអភិវឌ្ឍ

| វិមជ្ឈការ | វិសហមជ្ឈការ |
| --- | --- |
| - ទទួលខុសត្រូវផ្ទាល់ចំពោះអ្នកបោះឆ្នោត និងប្រយោលចំពោះរាជរដ្ឋាភិបាល<br>- តម្រូវឱ្យមានការចូលរួមពីប្រជាពលរដ្ឋ<br>- ថវិកា ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិ ដោយឡែក<br>- ទទួលអំណាច តាមរយៈការផ្ទេរពីថ្នាក់ជាតិ មានភាពជាម្ចាស់ក្នុងការអនុវត្ត | - ទទួលខុសត្រូវផ្ទាល់ចំពោះរាជរដ្ឋាភិបាល<br>- មិនតម្រូវឱ្យមានការចូលរួមពីប្រជាពលរដ្ឋ<br>- ថវិកា ហិរញ្ញវត្ថុ បុគ្គលិក ទ្រព្យសម្បត្តិជារបស់ជាតិ<br>- ទទួលអំណាច តាមរយៈការធ្វើប្រតិភូកម្មពីថ្នាក់ជាតិ<br>- អនុវត្តនីក្នុងនាមជាស្ថាប័នដែលធ្វើប្រតិភូកម្មឱ្យ |

# ៤. ដំណើរការនៃគម្រោងអភិវឌ្ឍន៍

ដំណើរការនៃគម្រោងអភិវឌ្ឍន៍អនុវត្តតាមជំហានសំខាន់ៗដូចខាងក្រោម :

- ការសិក្សាអំពីស្ថានភាព
- ការរៀបចំផែនការ
- ការអនុវត្តគម្រោង
- ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ




**ដំណើរការនៃគម្រោងអភិវឌ្ឍន៍ (វដ្តនៃគម្រោង)**

## ៤.១. ការសិក្សាអំពីស្ថានភាព

ការសិក្សាអំពីស្ថានភាព ជាជំហានដំបូងក្នុងដំណើរការនៃគម្រោងអភិវឌ្ឍន៍។ ការសិក្សាអំពីស្ថានភាពជួយឱ្យឃុំ សង្កាត់អាចយល់ដឹងអំពី :

- ល័ក្ខខ័ណ្ឌបច្ចុប្បន្នអំពីបញ្ហាសេដ្ឋកិច្ច សង្គម បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រង ។ល ។
- បញ្ហា ឬឧបសគ្គ ឬចំណុចខ្លាំង ចំណុចខ្សោយ ឬការប្រឈមនានាដែលកើតមានឡើង
- អ្នកណាខ្លះជាប់ពាក់ព័ន្ធនឹងបញ្ហាទាំងនោះ ហើយអ្នកទាំងនេះមានតួនាទីអ្វីខ្លះ
- លទ្ធភាពក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងសេដ្ឋកិច្ច សង្គម បរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រង ។ល ។ ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ។

ក្នុងការសិក្សាអំពីស្ថានភាព ឃុំ សង្កាត់បានប្រមូលព័ត៌មាន និងរៀបចំ :

- ព័ត៌មានស្ថានភាពឃុំ សង្កាត់
- ទិន្នន័យភូមិ
- ប្រព័ន្ធទិន្នន័យឃុំ សង្កាត់

## ក). គោលបំណងនៃការសិក្សាអំពីស្ថានភាព

ការសិក្សាអំពីស្ថានភាពមានគោលបំណង :

- ស្វែងយល់ពីបញ្ហា និងតម្រូវការជាមូលដ្ឋានសម្រាប់ធ្វើការវិភាគក្នុងការកំណត់សកម្មភាពអភិវឌ្ឍន៍ (បង្ហាញនូវស្ថានភាព និងបញ្ហា និងលទ្ធភាពក្នុងការដោះស្រាយ)
- ព័ត៌មានជាមូលដ្ឋានសម្រាប់វាយតម្លៃអំពីផលប៉ះពាល់របស់គម្រោង ។

### ខ). ព័ត៌មានដែលត្រូវលើកយកមកសិក្សា

ព័ត៌មានដែលត្រូវលើកយកមកសិក្សាអាចជាព័ត៌មានដែលពាក់ព័ន្ធនឹង :

- **ព័ត៌មានស្ថានភាពសេដ្ឋកិច្ច** : មុខរបរ ចំណូល ធនធាន និងមធ្យោបាយផលិតកម្មរបស់ប្រជាពលរដ្ឋ
- **ព័ត៌មានស្ថានភាពសង្គម** : បញ្ហាសុខភាព អនាម័យ ការអប់រំ យេនឌ័រ ការយល់ដឹង និងការអនុវត្តសិទ្ធិរបស់ប្រជាពលរដ្ឋ
- **ព័ត៌មានស្ថានភាពធនធានធម្មជាតិ និងបរិស្ថាន** : ធនធានព្រៃឈើក្នុងតំបន់ ធនធានទឹក ការទុកដាក់និងចោលកាកសំណល់ ការរងគ្រោះដោយធម្មជាតិ
- **ហេដ្ឋារចនាសម្ព័ន្ធ** : ស្ថានភាពប្រព័ន្ធគមនាគមន៍ ប្រព័ន្ធធារាសាស្ត្រ បណ្តាញផ្គត់ផ្គង់ទឹកស្អាត លំនៅស្ថានប្រជាពលរដ្ឋ
- . . . ។ល។

### គ). ប្រភពផ្តល់ព័ត៌មាន

ការប្រមូលព័ត៌មានអំពីតំបន់គោលដៅជាកត្តាមួយយ៉ាងសំខាន់ជួយឱ្យឃុំ សង្កាត់ទទួលបានព័ត៌មានជាក់លាក់សម្រាប់រៀបចំផែនការ។ ព័ត៌មានទាំងនេះអាចទទួលបានពីប្រជាពលរដ្ឋ ភូមិ ឃុំ សង្កាត់ និងបណ្តាឯកសារនានាដែលមាននៅក្នុងស្នាក់ការភូមិ សាលាឃុំ សង្កាត់ ។ល។ ព័ត៌មានទាំងនោះអាចជា :

- **ព័ត៌មានបឋម** : ព័ត៌មានដែលប្រមូលបានពីអ្នកផ្តល់ព័ត៌មានតាមរយៈ ការសម្ភាសន៍ និងការពិភាក្សា ។ល។

- **ព័ត៌មានមានស្រាប់ :** ជាព័ត៌មានដែលបានរៀបចំចងក្រងរួចជាស្រេច ដូចជា ទិន្នន័យភូមិ ស្ថានភាពឃុំ សង្កាត់ របាយការណ៍ និងស្ថិតិប្រជាពលរដ្ឋ ។ល ។

## ៤.២. ការរៀបចំផែនការអភិវឌ្ឍន៍

ការរៀបចំផែនការអភិវឌ្ឍន៍ គឺជាការកំណត់អំពីក្របខ័ណ្ឌអភិវឌ្ឍន៍ សកម្មភាព និងធនធានសម្រាប់អនុវត្ត ដើម្បីតម្រង់ទិសអភិវឌ្ឍន៍ឱ្យសម្រេចលទ្ធផលតាមការកំណត់ ។

ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ឃុំ សង្កាត់បានរៀបចំ :

- ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
- កម្មវិធីវិនិយោគឃុំ សង្កាត់
- . . . ។ល ។

### ក). សារប្រយោជន៍របស់ផែនការ

- តម្រង់ទិសអនុវត្តឱ្យចំទិសដៅ
- កំណត់អំពីលទ្ធភាពរបស់គម្រោង
- ប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព
- ផ្តល់ជាគំនិតដល់អ្នកអនុវត្ត
- ជួយឱ្យគម្រោងដំណើរការបានរលូន
- កំណត់ធនធាន និងការទទួលខុសត្រូវ
- អាចកំណត់អំពីលទ្ធផលរំពឹងទុក ។

## ខ). ក្របខ័ណ្ឌនៃការអភិវឌ្ឍ

ក្របខ័ណ្ឌនៃការអភិវឌ្ឍមាន : ចក្ខុវិស័យ គោលដៅ ទិសដៅ សកម្មភាព ធនធាន និងលទ្ធផលរំពឹងទុក។

### ខ.១). ចក្ខុវិស័យ

ចក្ខុវិស័យ គឺជាការប្រមើលអំពីទិដ្ឋភាព ឬ ស្ថានភាពមួយដ៏ល្អប្រសើរដែលចង់បាន ដើម្បីផ្តល់ជាគំនិតក្នុងការផ្តួចផ្តើមគោលដៅអភិវឌ្ឍន៍។

ចំណុចសំខាន់ៗដែលត្រូវពិចារណាក្នុងការរៀបចំចក្ខុវិស័យ :

- អ្វីដែលស្ថាប័នចង់បាននៅពេលអនាគត
- បង្ហាញពីលទ្ធផលចុងក្រោយដែលចង់បាន
- ផ្តល់ជាគំនិតសម្រាប់ការប្រឹងប្រែង ដើម្បីធ្វើឱ្យសម្រេច
- បង្ហាញអំពីទស្សនៈរបស់ស្ថាប័នទាំងមូលក្នុងរយៈពេលមួយវែង។

**ឧទាហរណ៍ :**

ឃុំសង្កាត់អាចមានចក្ខុវិស័យអភិវឌ្ឍន៍មួយចំនួនដូចជា :

- ប្រជាពលរដ្ឋទាំងអស់រស់នៅក្នុងសន្តិភាព យុត្តិធម៌ និងភាពសម្បូរសប្បាយ
- ប្រជាពលរដ្ឋមានសមត្ថភាព និងមានសិទ្ធិអំណាចគ្រប់គ្រាន់ក្នុងការចូលរួមសម្រេចចិត្តក្នុងការអភិវឌ្ឍ ដើម្បីធ្វើឱ្យសង្គមមានសមភាព សុខដុមរមនា និងសុភមង្គល។

### ១.២).គោលដៅ

គោលដៅ គឺជាការកំណត់អំពីលទ្ធផលរួមជាក់លាក់ដែលត្រូវសម្រេចឱ្យបាន ដើម្បីឆ្លើយតបនឹងចក្ខុវិស័យដែលបានកំណត់។

ចំណុចសំខាន់ៗដែលត្រូវពិចារណាក្នុងការរៀបចំគោលដៅ :

- បង្ហាញពីលទ្ធផលចុងក្រោយ ដែលឆ្លើយតបនឹងចក្ខុវិស័យ
- ផ្តល់គំនិតអនុវត្ត និងផ្តល់ជម្រើសក្នុងការអនុវត្តនៅពេលអនាគត
- មានលក្ខណៈជាយុទ្ធសាស្ត្រសម្រាប់ការអនុវត្ត
- បង្ហាញពីគំនិតមួយវែងឆ្ងាយ ប៉ុន្តែមានភាពជាក់លាក់។

**ឧទាហរណ៍**

គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាមានដូចខាងក្រោម :

- លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរ និងភាពអត់ឃ្លាន
- សម្រេចឱ្យបានជាទូទៅនូវការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំ
- លើកកម្ពស់សមភាពយេនឌ័រ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី
- កាត់បន្ថយអត្រាមរណភាពកុមារ
- លើកកម្ពស់សុខភាពមាតា
- ប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺដទៃទៀត
- ធានាចីរភាពបរិស្ថាន
- បង្កើតភាពជាដៃគូជាសាកលសម្រាប់កិច្ចអភិវឌ្ឍន៍
- ដោះមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការសង្គ្រោះជនរងគ្រោះ។

## ខ.៣).ទិសដៅ

ទិសដៅ គឺជាការកំណត់អំពីលទ្ធផលជាក់លាក់មួយដែលត្រូវសម្រេចឱ្យបាន ដើម្បីឆ្លើយតបនឹងគោលដៅដែលបានកំណត់។

ទិសដៅត្រូវមានលក្ខណៈសំខាន់ៗដូចខាងក្រោម :

- **ជាក់លាក់** : បង្ហាញពីលទ្ធផលដែលត្រូវធ្វើឱ្យសម្រេចបាន
- **អាចវាស់វែងបាន** : លទ្ធផលដែលអាចធ្វើការវាស់វែងបាន ដូចជា ភាគរយ ចំនួន ។ល។
- **អាចសម្រេចបាន** : ដែលអាចធ្វើទៅបាន និងសម្រេចតាមពេលកំណត់ប្រកបដោយហេតុផល
- **ប្រាកដប្រជា** : ជឿជាក់ថាអាចសម្រេចទៅបាន
- **ពេលវេលា** : ពេលវេលាដែលអាចធ្វើឱ្យសម្រេចលទ្ធផលបាន

**ឧទាហរណ៍**

ឃុំ សង្កាត់អាចមានទិសដៅអភិវឌ្ឍន៍មួយចំនួន ដូចជា :

- បង្កើនទិន្នផលស្រូវឱ្យបាន៣តោនក្នុងមួយហិកតាក្នុងឆ្នាំ២០១២
- ផ្តល់អគ្រានុកូលដ្ឋានដល់ប្រជាពលរដ្ឋក្នុងឃុំឱ្យបាន១០០% ក្នុងឆ្នាំ២០១២
- បង្កើនការប្រើប្រាស់បង្គន់អនាម័យតាមគ្រួសាររបស់ប្រជាពលរដ្ឋក្នុងឃុំឱ្យបាន៨០% ក្នុងឆ្នាំ២០១២។

**ភាពខុសគ្នារវាងគោលដៅ និងទិសដៅ**

| គោលដៅ | ទិសដៅ |
|---|---|
| - ការពណ៌នាខ្លីៗ<br>- វិសាលភាពទូលាយ<br>- មានរយៈពេលវែង (ដូចជា ៥ឆ្នាំ) | - ការពណ៌នាអាចវែង<br>- វិសាលភាពតូចចង្អៀត<br>- មានរយៈពេលខ្លី (ដូចជា ១ឆ្នាំ យោងតាមឆ្នាំសារពើពន្ធ) |

## ១.៤). សកម្មភាព

សកម្មភាព គឺជាការកំណត់អំពីកិច្ចការដែលត្រូវអនុវត្ត ដើម្បីបង្កើតឱ្យបានលទ្ធផលជាក់លាក់មួយតាមទិសដៅកំណត់។

### ឧទាហរណ៍

ឃុំ សង្កាត់អាចមានសកម្មភាពអភិវឌ្ឍន៍មួយចំនួន ដូចជា :

- សាងសង់ប្រឡាយ និងទំនប់ទឹក
- បណ្តុះបណ្តាលបច្ចេកទេសដាំដំណាំស្រូវ
- បណ្តុះបណ្តាលបច្ចេកទេសធ្វើជីកំប៉ុស្ត៍
- ធ្វើស្រែបង្ហាញអំពីបច្ចេកទេសដាំដុះដំណាំស្រូវ
- . . . ។ល។

## ១.៥). ធនធាន

ធនធាន សំដៅលើធនធានហិរញ្ញវត្ថុ សម្ភារៈ មធ្យោបាយនានា ពេលវេលា និងធនធានមនុស្ស ។ល។ ដែលត្រូវការសម្រាប់អនុវត្តសកម្មភាព។

ធនធានទាំងនោះត្រូវបានប៉ាន់ស្មាន និងគ្រោងនៅក្នុងផែនការ ដើម្បីធានាថា ក្នុងអំឡុងពេលអនុវត្ត ធនធានទាំងនោះ (បរិមាណ និងគុណភាព) អាចទ្រទ្រង់ដំណើរការអភិវឌ្ឍន៍បានប្រកបដោយប្រសិទ្ធភាព។

ក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់បានគ្រោងធនធានមួយចំនួន ដូចជា :

- តម្លៃគម្រោង : មូលនិធិឃុំ សង្កាត់ ឬប្រភពទុនវិនិយោគ
- ពេលវេលា : កាលវិភាគដែលត្រូវអនុវត្ត (ឆ្នាំ)
- ...។ល។

### ខ.៦). លទ្ធផលរំពឹងទុក

លទ្ធផលរំពឹងទុក គឺជាលទ្ធផលគ្រោងរបស់គម្រោងដែលត្រូវធ្វើឱ្យសម្រេចបាន។ លទ្ធផលរំពឹងទុកនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់មាន :

- បរិមាណនៃលទ្ធផល ដូចជា ចំនួនវគ្គបណ្តុះបណ្តាល ចំនួនស្ពាន ប្រវែងផ្លូវថ្នល់ ប្រវែងប្រឡាយ និងចំនួនអណ្តូង។ល។
- អ្នកទទួលផល ដូចជា ចំនួនសរុប ស្ត្រី ចំនួនគ្រួសារ និងប្រភេទអ្នកទទួលផល។ល។

## ៤.៣. ការអនុវត្តគម្រោង

ការអនុវត្តគម្រោង គឺជាការអនុវត្តសកម្មភាពដែលបានកំណត់ក្នុងផែនការដោយប្រើប្រាស់ធនធាន (មនុស្ស ថវិកា ពេលវេលា។ល។) ដើម្បី

បង្កើតបានលទ្ធផលតាមផែនការគ្រោងទុក។ គម្រោងមូលនិធិឃុំ សង្កាត់អាច ជាគម្រោងហេដ្ឋារចនាសម្ព័ន្ធ ឬគម្រោងសេវាកម្ម។

ផ្អែកលើកម្មវិធីវិនិយោគឃុំ សង្កាត់ និងធនធានរបស់ឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់បានអនុវត្តគម្រោងមួយចំនួនដូចជា :

- **គម្រោងហេដ្ឋារចនាសម្ព័ន្ធ :**
  - សាងសង់ទំនប់ ស្ពានប្រឡាយ និងសាងសង់សំណង់ស្ទាក់ទឹក
  - សាងសង់ផ្លូវថ្នល់ ស្ពាន លូបង្ហូរទឹក
  - សាងសង់អគារសិក្សា
  - សាងសង់មណ្ឌលសុខភាព បុស្តិ៍សុខភាព
  - ជីកស្រះ និងអណ្តូងទឹក
  - សាងសង់ទួលសុវត្ថិភាពការពារទឹកជំនន់
- **គម្រោងសេវាកម្ម**
  - បណ្តុះបណ្តាលបច្ចេកទេសកសិកម្មដំណាំស្រូវ
  - ចាក់វ៉ាក់សាំងការពារជំងឺដល់សត្វពាហនៈ
  - ផ្សព្វផ្សាយប្រជាពលរដ្ឋឱ្យបញ្ជូនកូនទៅរៀន
  - រៀបចំដំណើរការមត្តេយ្យសិក្សាសហគមន៍
  - ការអប់រំផ្សព្វផ្សាយប្រជាពលរដ្ឋប្រើប្រាស់ទឹកមានសុវត្ថិភាព
  - ផ្សព្វផ្សាយប្រជាពលរដ្ឋបញ្ជូនកូនទៅចាក់វ៉ាក់សាំង
  - . . . ។ល។

## ក). ការរៀបចំគម្រោង

ការរៀបចំគម្រោងអនុវត្តតាមជំហានដូចខាងក្រោម :

### ក.១). សិក្សាលទ្ធភាព

ចំពោះគម្រោងហេដ្ឋារចនាសម្ព័ន្ធ ការសិក្សាលទ្ធភាព ជាការសិក្សាអំពីល័ក្ខខ័ណ្ឌទីតាំងគម្រោង ដើម្បីរៀបចំគម្រោងការ និងគំនូសប្លង់បច្ចេកទេសឱ្យស្របតាមស្ថានភាពជាក់ស្តែង។ លទ្ធផលសិក្សាលទ្ធភាពត្រូវបានរៀបចំជាព័តិមានគម្រោង។

ចំពោះគម្រោងសេវាកម្ម គឺជាការប៉ាន់ប្រមាណតម្រូវការរបស់អ្នកទទួលផល ដើម្បីឱ្យដឹងថា អ្នកទទួលផលត្រូវការសេវាអ្វីខ្លះ បង្កើនសមត្ថភាពអ្វីខ្លះ ឬបណ្តុះបណ្តាលលើខ្លឹមសារអ្វី។ ដើម្បីធ្វើការប៉ាន់ប្រមាណតម្រូវការវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅណាមួយត្រូវសិក្សា :

- សមត្ថភាព( ចំណេះដឹង ជំនាញ និងឥរិយាបថ) ក្រុមគោលដៅ
- មុខងារ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមគោលដៅ
- ក្របខ័ណ្ឌអភិវឌ្ឍន៍របស់ស្ថាប័ន ( ចក្ខុវិស័យ បេសកកម្ម...)

### ក.២). សិក្សាផលប៉ះពាល់

ការសិក្សាផលប៉ះពាល់សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធជាកិច្ចការមួយចាំបាច់ ដើម្បីស្វែងរកផលប៉ះពាល់របស់គម្រោងទៅលើធនធានធម្មជាតិ បរិស្ថាន ដីធ្លី វប្បធម៌ និងចាត់វិធានការដោះស្រាយ មុននឹងអនុវត្តគម្រោង។

### ក.៣). រៀបចំព័ត៌មានគម្រោង

ព័ត៌មានសិក្សាលទ្ធភាព និងការសិក្សាផលប៉ះពាល់ត្រូវបានប្រើប្រាស់សម្រាប់រៀបចំព័ត៌មានគម្រោង។ ព័ត៌មានគម្រោងហេដ្ឋារចនាសម្ព័ន្ធត្រូវមានព័ត៌មានសំខាន់ៗ ដូចជា :

- របាយការណ៍សិក្សាផលប៉ះពាល់
- ផែនទីទីតាំងគម្រោង
- គ្រោងការគម្រោង ឬគំនូសប្លង់បច្ចេកទេស
- តារាងប៉ាន់ស្មានតម្លៃ។

### ខ). លទ្ធកម្ម និងការគ្រប់គ្រងគម្រោង

គម្រោងអភិវឌ្ឍន៍មូលនិធិឃុំ សង្កាត់ត្រូវបានអនុវត្តដោយអ្នកទទួលការ ហេតុនេះ អ្នកទទួលការដែលទទួលបានគម្រោងឃុំ សង្កាត់ទៅអនុវត្តត្រូវបានជ្រើសរើសឡើង តាមរយៈការធ្វើលទ្ធកម្ម។

សកម្មភាព និងលទ្ធផលដែលអ្នកទទួលការត្រូវអនុវត្តនឹមានចែងក្នុងកិច្ចសន្យា។ កិច្ចសន្យាធ្វើឡើងរវាងមេឃុំ ចៅសង្កាត់ និងអ្នកទទួលការ ហេតុនេះ មេឃុំ ចៅសង្កាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងកិច្ចសន្យានោះ។ ឯកសារកិច្ចសន្យាត្រូវមានព័ត៌មាន :

- ល័ក្ខខ័ណ្ឌនៃកិច្ចសន្យា
- គំនូសប្លង់ និងសេចក្ដីលម្អិតបច្ចេកទេស
- ផែនទីគម្រោង

- សំណើដេញថ្លៃ
- លទ្ធផល និងតម្លៃកិច្ចសន្យា
- ផែនការការងាររបស់អ្នកទទួលការ

នៅក្នុងដំណាក់កាលអនុវត្តន៍គម្រោងអភិវឌ្ឍន៍មូលនិធិឃុំ សង្កាត់ ឃុំ សង្កាត់ត្រូវរៀបចំគណៈកម្មការគ្រប់គ្រងគម្រោង ដើម្បីតាមដានត្រួតពិនិត្យ និងវាយតម្លៃគម្រោង។

ចំពោះ គម្រោងមួយចំនួនដែលត្រូវអនុវត្តន៍ដោយឃុំ សង្កាត់ផ្ទាល់ ដូចជា គម្រោងអភិវឌ្ឍន៍ផ្នែកសង្គម ឃុំ សង្កាត់អាចប្រើប្រាស់ធនធានមនុស្សរបស់ឃុំ ដើម្បីគ្រប់គ្រង និងអនុវត្តសកម្មភាពគម្រោងទាំងនោះ។

## ៤.៤. ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

### ក). និយមន័យនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

#### ក.១). ការតាមដានត្រួតពិនិត្យ

ការតាមដានត្រួតពិនិត្យ គឺជាដំណើរការនៃការប្រមូលព័ត៌មានពីការរីកចម្រើន និងបញ្ហាជួបប្រទះនៃការអនុវត្តសកម្មភាព ដើម្បីឱ្យដឹងថាសកម្មភាព និងលទ្ធផលដែលបានអនុវត្តស្របតាមផែនការ និងរួមចំណែកសម្រេចនូវទិសដៅដែលបានកំណត់។

#### ក.២).ការវាយតម្លៃ

ការវាយតម្លៃ គឺជាដំណើរការប្រមូលព័ត៌មាន ដើម្បីផ្ទៀងផ្ទាត់ និងវាស់វែងអំពីលទ្ធផល ប្រសិទ្ធភាព និងផលប៉ះពាល់នៃការអនុវត្តគម្រោង។

### ខ). គោលបំណងនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃមានគោលបំណង :

- ជួយពង្រឹងគណនេយ្យភាព
- កែលម្អការគ្រប់គ្រង និងការសម្រេចចិត្ត
- ជំរុញឱ្យមានការរៀនសូត្រ
- ធានាគុណភាព និរន្តរភាព និងប្រសិទ្ធភាពនៃការអនុវត្ត ។

### គ). ប្រភេទនៃការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

ជាទូទៅការតាមដានត្រួតពិនិត្យ និងការវាយតម្លៃមានពីរប្រភេទគឺ :

- ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃផ្ទៃក្នុង
- ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃពីខាងក្រៅ ។

### ឃ). សមាសភាគគម្រោងត្រូវតាមដានត្រួតពិនិត្យ និងការវាយតម្លៃ

សមាសភាគគម្រោងត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃមាន :

- ធនធាន : ហិរញ្ញវត្ថុ ពេលវេលា សម្ភារៈ ឬឧបករណ៍ និងមនុស្ស
- សកម្មភាព : ការសាងសង់ ការផ្គត់ផ្គង់សម្ភារៈ ឬការផ្តល់សេវា
- លទ្ធផល : សំណង់ សម្ភារៈ ការយល់ដឹង អ្នកទទួលផល
- ផលប៉ះពាល់ : ស្ថានភាពជីវភាព បំណិនជីវិត

### ង). ការរៀបចំតាមដានត្រួតពិនិត្យ និងវាយតម្លៃ

ការរៀបចំតាមដានត្រួតពិនិត្យ និងវាយតម្លៃមានជំហានដូចខាងក្រោម :

- កំណត់គោលបំណង : តើតាមដានត្រួតពិនិត្យ និងវាយតម្លៃលើអ្វី? តើលទ្ធផលតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រើប្រាស់ដើម្បីអ្វី?
- កំណត់សូចនាករ : កំណត់ព័ត៌មានដែលត្រូវការ
- កំណត់សំណួរគន្លឹះ : រៀបចំបញ្ជីសំណួរស្របតាមសូចនាករ
- កំណត់វិធីសាស្ត្រ : សង្កេត សម្ភាសន៍ ពិភាក្សា បំពេញបញ្ជីសំណួរ
- ការរៀបចំផែនការតាមដានត្រួតពិនិត្យ និងវាយតម្លៃ ។

**ច). ការអនុវត្តការតាមដានត្រួតពិនិត្យ និងការវាយតម្លៃ**

ការអនុវត្តការតាមដានត្រួតពិនិត្យត្រូវធ្វើឡើងជាប្រចាំនៅក្នុងអំឡុងពេលអនុវត្ត ហើយការវាយតម្លៃធ្វើឡើងនៅអំឡុងពេលជាក់លាក់ណាមួយ ដូចជា ពាក់កណ្តាលគម្រោង ពេលបញ្ចប់គម្រោង និងក្រោយពេលបញ្ចប់គម្រោងមួយរយៈ ។ ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃអាចធ្វើឡើងតាមរយៈ :

- ការប្រមូលព័ត៌មាននៅទីតាំងគម្រោង : សង្កេត សម្ភាសន៍ ពិភាក្សា ឬបំពេញបញ្ជីសំណួរជាមួយអ្នកគ្រប់គ្រង អ្នកអនុវត្ត និងអ្នកទទួលផលគម្រោង ឬតាមវិធីសាស្ត្រផ្សេងៗទៀត ។ល។
- ពិនិត្យរបាយការណ៍ ឬកំណត់ហេតុ : របាយការណ៍រីកចម្រើននៃកិច្ចសន្យា របាយការណ៍បញ្ចប់កិច្ចសន្យា របាយការណ៍សវនកម្មបច្ចេកទេស ប្រព័ន្ធទិន្នន័យនៃការអនុវត្តគម្រោង ។ល។
- ការធ្វើសវនកម្មបច្ចេកទេស ។

# ឯកសារយោង


១. ទស្សនៈនៃការអភិវឌ្ឍ http://www.google.com/search?hl=en&q=The+Concept+of+Development&btnG=Search&aq=f&aqi=g2&aql=&oq=&gs_rfai=

២. សូចនាករសំខាន់ៗនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាព http://www.mofa.go.jp/policy/economy/eismap/k_seminar/Round-2-3.pdf

៣. ការងារសង្គម និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព http://www.google.com/search?hl=en&q =Social+work+and+sustainable+development&btnG=Search&aq=f&aqi=&aql=&oq=&gs_rfai=

៤. ទំនាក់ទំនងរវាងការអប់រំ និងការអភិវឌ្ឍ http://www2.unescobkk.org/elib/publications/TrainingManual/MODULE1.PDF

៥. ការអភិវឌ្ឍស្ថាប័ន http://www.google.com/search?hl=en&q=Organization+development+ppt&btnG=Search&aq=f&aqi=g-s1g-m1g-msx3&aql=&oq=&gs_rfai=

៦. គោលការណ៍ណែនាំ ស្តីពី ការកសាងសមត្ថភាពក្នុងវិស័យអប់រំ http://www.google.com/search?hl=en&q=Guidelines+for+Capacity+ Development+in+Education+Sector&btnG=Search&aq=f&aqi=&aql=&oq=&gs_rfai=

៧. ការអប់រំ ដើម្បីអភិវឌ្ឍន៍ប្រកដោយនិរន្តរភាព http://www.esdtoolkit.org/discussion/default.htm)

៨. ផែនការយុទ្ធសាស្ត្រសម្រាប់ការអប់រំ http://www.iiep.unesco.org/fileadmin/user_upload/Research_Challenges_and_Trends/pdf/symposium/ChangGwangChol.pdf)

៩. សិទ្ធិមនុស្ស វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ ឆ្នាំ២០០៤

១០. ការអភិវឌ្ឍផ្អែកលើសិទ្ធិជាមូលដ្ឋាន http://www.google.com/search?hl=en&q=what+is+a+rights-based+approach+to+development&aq=0l&aqi=g-l1&aql=&oq =what+is+a+righs-base+approach&gs_rfai=

១១. ប្រភេទនៃគណនេយ្យភាព http://en.wikipedia.org/wiki/Accountability

១២. វិមជ្ឈការ http://en.wikipedia.org/wiki/Decentralization

១៣. បរិស្ថាន សៀវភៅជំនួយស្មារតី ក្រសួងបរិស្ថាន ឆ្នាំ២០០០

១៤. វដ្តនៃការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ http://www.proventionconsortium.org/themes/default/pdfs/tools_for_mainstreaming_GN5.pdf